Public Disclosure Authorized

Public Disclosure Authorized

មាតិកា

បុព្វកថា ๑

ពាក្យសរសេរជាអក្សរកាត់ ๒

I- សេចក្តីផ្តើម ๓

II- គោលនយោបាយ ๖

ក. ករណីលើកលែង ๖

ខ. បុព្វសិទ្ធិរបស់ធនាគារពិភពលោកក្នុងការចេញផ្សាយព័ត៌មានហាមឃាត់ ๑๑

គ. បុព្វសិទ្ធិរបស់ធនាគារពិភពលោកចំពោះការទទួលបានព័ត៌មានហាមឃាត់ ๑๒

III- ព័ត៌មានទាក់ទងទៅនឹងបណ្តាប្រទេសជាសមាជិកនិងតាតិជនៀតៗទៀត ๑๒

IV- និដ្ឋភាពនៃការអនុវត្តគោលនយោបាយ ๑๔

ក. ការទទួលបានព័ត៌មាន ๑๕

ខ. ការចាត់ចំណាត់ថ្នាក់ ๑๗

គ. ការប្រកាសជាផ្លូវការ ๑๘

ឃ. សារអេឡិចត្រូនិច ๒๐

ង. គណកម្មាធិការផ្តល់ព័ត៌មាន ๒๒

ច. បណ្តឹងឧទ្ធរណ៍ ๒๓

សេចក្តីបន្ថែម : ប្រភពព័ត៌មានរបស់ធនាគារពិភពលោក ๒๗

បុព្វកថា

ខ្ញុំមានសេចក្តីរីករាយក្នុងការបង្ហាញអំពីគោលនយោបាយថ្មីរបស់ធនាគារពិភពលោកស្តីអំពីការទទួលបានព័ត៌មាន។ គោលនយោបាយថ្មីនេះធ្វើឱ្យមានការផ្លាស់ប្តូរមួយដ៏សំខាន់ក្នុងវិធីសាស្ត្ររបស់ធនាគារពិភពលោកក្នុងការផ្សព្វផ្សាយព័ត៌មាន តម្លាភាព ការចែករំលែកចំណេះដឹង និងគណនេយ្យភាព។ បច្ចុប្បន្ននេះសាធារណជនអាចទទួលបានព័ត៌មានកាន់តែទូលំទូលាយជាងមុន ដែលមិនធ្លាប់មានពីមុន ជាពិសេស ព័ត៌មានអំពីគម្រោងនានាដែលកំពុងរៀបចំ និងអនុវត្ត និងសកម្មភាពរបស់ក្រុមប្រឹក្សាភិបាល។

យើងជឿថាគោលនយោបាយថ្មីនេះនឹងធ្វើឱ្យប្រសើរឡើងដល់គុណភាពនៃការងាររបស់យើង និងពង្រឹងកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់របស់ធនាគារពិភពលោកស្តីពីការអភិវឌ្ឍជាមួយគ្រប់បណ្តាភាគីពាក់ព័ន្ធទាំងអស់។ យើងសង្ឃឹមថាគោលនយោបាយថ្មីនេះនឹងជំរុញឱ្យមានការវិភាគថ្មីៗ ការពិភាក្សា និងការស្រាវជ្រាវតាមលំដាប់នៃផ្នែកផ្សេងៗក្នុងការងារអភិវឌ្ឍន៍ ដែលអាចចូលរួមចំណែកចំពោះសមិទ្ធិផលនៃបេសកកម្មរបស់ធនាគារពិភពលោកក្នុងការប្រឆាំងនឹងភាពក្រីក្រ និងជំរុញឱ្យមានកំណើន។ យើងសង្ឃឹមថាគោលនយោបាយនេះនឹងបង្កើតឱ្យមានភាពជាដៃគូ និងការអនុវត្តភាពសម្រាប់ដំណោះស្រាយថ្មីៗនិងវិធីសាស្ត្រនានាក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងការងារអភិវឌ្ឍន៍ដែលយើងជួបប្រទះនៅក្នុងពិភពលោកទាំងមូល ដែលកំពុងតែវិវត្តយ៉ាងលឿននាពេលបច្ចុប្បន្ន។

លោក រ៉ូប៊ឺត បី. ហ្សូលីក

ប្រធាន

ពាក្យសរសេរជាអក្សរកាត់

AI	លទ្ធភាពទទួលបានព័ត៌មាន
AMS	សៀវភៅណែនាំស្តីអំពីការងាររដ្ឋបាល
CAS	យុទ្ធសាស្ត្រជំនួយប្រចាំប្រទេស
CPIA	ការវាយតំលៃលើគោលនយោបាយប្រចាំប្រទេស និងស្ថាប័ន
CPPR	ការត្រួតពិនិត្យមើលឡើងវិញលើប្រតិបត្តិការនៃគម្រោងប្រចាំប្រទេស
DPO	ប្រតិបត្តិការគោលនយោបាយអភិវឌ្ឍន៍
FSAP	កម្មវិធីវាយតំលៃវិស័យហិរញ្ញវត្ថុ
HIPC	ប្រទេសក្រីក្រដែលជំពាក់បំណុលគេច្រើន
IBRD	ធនាគារអន្តរជាតិសំរាប់ការស្តារឡើងវិញ និងការអភិវឌ្ឍ
ICR	របាយការណ៏បញ្ចប់ និងលទ្ធផលនៃការអនុវត្ត
ICSID	មជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយជំលោះវិនិយោគទុន
IDA	សមាគមន៍អភិវឌ្ឍអន្តរជាតិ
IEG	ក្រុមវាយតំលៃឯករាជ្យ
IFC	សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ
INT	នាយកដ្ឋានសុក្រិតភាពស្ថាប័ន
IP	ក្រុមអធិការកិច្ច
MIGA	ទីភ្នាក់ងារធានាវិនិយោគទុនពហុភាគី
MOS	សេចក្តីសង្ខេបប្រតិបត្តិប្រចាំខែ
MCO	លិខិតស្តីអំពីប្រតិបត្តិការដែលត្រូវបានលុបចោល
OP/BP	គោលនយោបាយប្រតិបត្តិ/នីតិវិធីរបស់ធនាគារពិភពលោក
PRSP	ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ
QAG	ក្រុមធានាគុណភាព
SOPE	ស្ថានភាពនៃគម្រោងកំពុងប្រតិបត្តិ
SSP	ឯកសារយុទ្ធសាស្ត្រតាមវិស័យ
UCS	ការប្រើប្រាស់ប្រព័ន្ធប្រចាំប្រទេស
WBG	ក្រុមធនាគារពិភពលោក

គោលនយោបាយរបស់ធនាគារពិភពលោកស្តីអំពីលទ្ធភាពទទួលបានព័ត៌មាន

ការបោះពុម្ពផ្សាយនេះមានគោលបំណងបង្ហាញអំពីគោលនយោបាយរបស់ធនាគារពិភពលោកស្តីពីលទ្ធភាពទទួលបានព័ត៌មាន ជាលក្ខណៈសាធារណៈ។ គោលនយោបាយនេះជំនួសឱ្យគោលនយោបាយរបស់ធនាគារពិភពលោកស្តីពីការផ្សព្វផ្សាយព័ត៌មាន បើយ នឹងចូលជាធរមាននៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០។

I- សេចក្តីផ្តើម

១. ធនាគារពិភពលោក[1] ទទួលស្គាល់ថា តម្លាភាពនិងគណនេយ្យភាព គឺមានសារៈសំខាន់ជាមូលដ្ឋានចំពោះដំណើរការអភិវឌ្ឍន៍ និងសម្រេចបាននូវបេសកកម្មរបស់ខ្លួនក្នុងការកាត់បន្ថយភាពក្រីក្រ។ តម្លាភាពមានសារៈសំខាន់ចំពោះការកសាងនិងរក្សានូវការពិភាក្សា ផ្លាស់ប្តូរយោបល់ជាសាធារណៈ និងបង្កើនការយល់ដឹងជាសាធារណៈអំពីតួនាទី និងបេសកកម្មនៃការអភិវឌ្ឍរបស់ធនាគារពិភពលោក។ វាក៏មានសារៈសំខាន់ផងដែរចំពោះការលើកកម្ពស់អភិបាលកិច្ចល្អ គណនេយ្យភាព និងប្រសិទ្ធិភាពនៃការអភិវឌ្ឍ។ ភាពបើកចំហ ជំរុញឱ្យមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធនានា ដែលជាបន្តបន្ទាប់វានឹងធ្វើឱ្យប្រសើរឡើងដល់រចនាបទ និងការអនុវត្តនៃគម្រោងនិងគោលនយោបាយនានា និងពង្រឹងលទ្ធផលនៃការអភិវឌ្ឍ។ វាសម្របសម្រួលដល់ការគ្រប់គ្រងជាសាធារណៈលើប្រតិបត្តិការនានាដែលគាំទ្រដោយធនាគារពិភពលោក ក្នុងកំឡុងពេលនៃការរៀបចំ និងអនុវត្តរបស់ខ្លួនដែលមិនត្រឹមតែជួយគាំទ្រដល់ការបង្ហាញអំពីការប្រព្រឹត្តខុស និងអំពើពុករលួយធ្ងន់ធ្ងរប៉ុណ្ណោះទេ ក៏ប៉ុន្តែ ថែមទាំងលើកកម្ពស់ដល់លទ្ធភាពដែលបញ្ហានានា នឹងត្រូវបានចង្អុលបង្ហាញ និងដោះស្រាយនៅពេលបន្ទាប់។

២. ដោយសារធនាគារពិភពលោកត្រូវបានគេទទួលស្គាល់ឃ្លាតយាមកហើយ នោះគោលនយោបាយស្តីពីលទ្ធភាពទទួលបានព័ត៌មានដែលមានលក្ខណៈបើកចំហ និងល្អត្រឹមត្រូវគឺមានសារៈសំខាន់ជាមូលដ្ឋានក្នុងការបំពេញនូវតួនាទីជាច្រើនរបស់ខ្លួន។

---

[1] សម្រាប់គោលបំណងនៃការបោះពុម្ពផ្សាយគោលនយោបាយនេះ ពាក្យថា "ធនាគារពិភពលោក" ឬ "ធនាគារ" មានន័យថាជាធនាគារអន្តរជាតិសម្រាប់ការស្តារឡើងវិញ និងការអភិវឌ្ឍ (IBRD) និងសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) "ក្រុមធនាគារពិភពលោក" រួមមាន IBRD, IDA សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ទីភ្នាក់ងារធានារ៉ាប់រងការវិនិយោគទុនពហុភាគី (MIGA) និងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ដោះស្រាយជម្លោះវិនិយោគទុន (ICSID) "កម្ចី" អាចរួមមានឥណទាន IDA និងជំនួយបច្ចេកទេស ជំនួយបច្ចេកទេសដែលបានមកពីប្រាក់ចំណូលសុទ្ធរបស់ធនាគារពិភពលោក និងថវិការដ្ឋបាល និងជំនួយបច្ចេកទេសមូលនិធិមរតក។ "អ្នកខ្ចី" រួមមានអ្នកទទួលឥណទាន និងអ្នកទទួលជំនួយបច្ចេកទេស និងអ្នកធានា។ "ព័ត៌មាន" រួមមានឯកសារគ្រប់ប្រភេទ (ឧទាហរណ៍ ឯកសារការងារ ឯកសារអេឡិចត្រូនិក រូបថត ភាពយន្ត ឯកសារកត់ត្រាជាសំលេង និងខ្សែវីដេអូ) ដែលបានរៀបចំឬបានទទួលដោយធនាគារពិភពលោកក្នុងគោលបំណងទុកសម្រាប់ប្រើប្រាស់ផ្លូវការរបស់ខ្លួន។ "ភាគីចំបី" រួមមាន បុគ្គល បុគ្គលជាក្រុម អង្គការ វីអង្គភាពដទៃផ្សេងទៀតផ្តល់ព័ត៌មានមកឱ្យធនាគារពិភពលោក។ ពាក្យថា "ផ្សព្វផ្សាយ" "ផ្តល់លទ្ធភាព" និង "ផ្សព្វផ្សាយជាសាធារណៈ" (និងពាក្យកម្មាយរបស់វាជាច្រើនទៀត) ត្រូវបានប្រើប្រាស់ផ្លាស់ប្តូរគ្នានៅក្នុងគោលនយោបាយនេះ។ គោលនយោបាយនេះអាចនឹងត្រូវបានកែតំរូវយ៉ូរ១ម្តង។

- ក្នុងនាមជាស្ថាប័នហិរញ្ញវត្ថុអភិវឌ្ឍន៍មួយ ធនាគារពិភពលោកព្យាយាមធ្វើឱ្យមានតម្លាភាពអំពីគម្រោង និងកម្មវិធីរបស់ខ្លួន (ជាពិសេសជាមួយក្រុមគោលដៅស្ថិតនៅក្នុងប្រតិបត្តិការរបស់ខ្លួន) ដើម្បីចែករំលែកនូវចំណេះដឹង និងមេរៀននៃបទពិសោធន៍ដែលមានលក្ខណៈជាសកលរបស់ខ្លួនជាមួយនឹងអ្នកអាន ឬស្តាប់ព័ត៌មានយ៉ាងច្រើនបំផុត និងដើម្បីលើកកម្ពស់គុណភាពនៃប្រតិបត្តិការរបស់ខ្លួនតាមរយៈការធ្វើឱ្យភាគីពាក់ព័ន្ធចូលរួមបានច្រើន។
- ក្នុងនាមជាអង្គការអន្តររដ្ឋាភិបាលមួយដែលមានប្រទេសជាច្រើនជាសមាជិក ធនាគារពិភពលោកមានគណនេយ្យភាពចំពោះថវិកាសាធារណៈ និងមានកាតព្វកិច្ចមួយដើម្បីឆ្លើយតបទៅនឹងសំណួរនានា និងកង្វល់របស់ភាគីពាក់ព័ន្ធទាំងអស់របស់ខ្លួន។
- ក្នុងនាមជាអ្នកខ្ចី ធនាគារពិភពលោកបានអះអាងថា ការផ្សព្វផ្សាយព័ត៌មានដែលមានសារៈសំខាន់ វានឹងជួយទាក់ទាញអ្នកទិញជាច្រើនឱ្យទិញភាគប៉ុនរបស់ខ្លួន។
- ក្នុងនាមជានិយោជក ធនាគារពិភពលោកស្វះស្វែងផ្តល់ដល់និយោជិតរបស់ខ្លួននូវព័ត៌មានទាំងអស់ដែលពួកគេត្រូវការដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

៣. ស្របពេលជាមួយគ្នានោះដែរ ធនាគារពិភពលោកមានកាតព្វកិច្ចមួយដើម្បីការពារនូវភាពសម្ងាត់នៃព័ត៌មានសំខាន់ៗ។ គោលនយោបាយនេះព្យាយាមសំរេចឱ្យបាននូវតុល្យភាពសមស្របមួយរវាងតំរូវការ ដើម្បីផ្តល់ឱ្យនូវលទ្ធភាពទទួលបានព័ត៌មានជាលក្ខណៈសាធារណៈឱ្យបានច្រើនជាអតិបរមា ដែលធនាគារពិភពលោកមាន និងកាតព្វកិច្ចរបស់ធនាគារពិភពលោក ក្នុងការរក្សានូវភាពសម្ងាត់នៃអតិថិជនរបស់ខ្លួន អ្នកកាន់ភាគប៉ុន និយោជិត និងភាគីដទៃផ្សេងទៀត។

៤. ធនាគារពិភពលោកក៏ទទួលស្គាល់ផងដែរអំពីសារៈសំខាន់នៃការបកស្រាយព័ត៌មានដែលខ្លួនបង្កើតឡើង។ វិធីសាស្ត្ររបស់ធនាគារពិភពលោកក្នុងការបកស្រាយត្រូវបានចែងនៅក្នុងក្របខណ្ឌបកប្រែរបស់ធនាគារពិភពលោក ហើយធនាគារពិភពលោកបកប្រែឯកសារនានាទៅជាភាសាសមស្របដោយអនុលោមទៅតាមក្របខណ្ឌនោះ។

៥. ***គោលការណ៍ណែនាំ*** គោលនយោបាយនេះផ្អែកលើគោលការណ៍ចំនួន ៥ :

- បង្កើនលទ្ធភាពទទួលបានព័ត៌មានឱ្យបានកម្រិតអតិបរមា
- កំណត់ច្បាស់នូវបញ្ជីរាយនាមករណីលើកលែង
- ការពារដំណើរការដែលពាក់ព័ន្ធ នឹងការសម្រេចចិត្ត
- ផ្តល់នូវនីតិវិធីច្បាស់លាស់សម្រាប់ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ
- ទទួលស្គាល់អំពីសិទ្ធិរបស់អ្នកស្នើសុំចំពោះដំណើរការបណ្តឹងឧទ្ធរណ៍

គោលនយោបាយនេះត្រូវបានចែកចេញជា ៤ ផ្នែក។ បន្ទាប់ពីសេចក្តីផ្តើមនេះ ផ្នែកទី២ចែងអំពីគោលនយោបាយស្នូល ផ្នែកទី៣ចែងអំពីរបៀបដែលធនាគារពិភពលោកគ្រប់គ្រងព័ត៌មានទាក់ទងទៅនឹងបណ្តាប្រទេសជាសមាជិក និងភាគីដទៃៗទៀត និងផ្នែកទី៤ ចែងអំពីទិដ្ឋភាពនៃការអនុវត្តគោលនយោបាយនេះ។

II- គោលនយោបាយ

៦. ធនាគារពិភពលោកអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មាននានាដែលខ្លួនមាន ដែលមិនស្ថិតនៅក្នុងបញ្ជីរាយនាមករណីលើកលែង (ចែងនៅក្នុងភាគទី២ ផ្នែក ក នៃគោលនយោបាយនេះ)។ ក្រៅពីនេះ ជាយថាហេតុធនាគារពិភពលោកប្រកាសជាផ្លូវការ និងផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានជាក់លាក់ដែលស្ថិតនៅក្នុងករណីលើកលែង (ដូចដែលបានចែងនៅក្នុង ភាគទី៤ ផ្នែក គ នៃគោលនយោបាយនេះ)។ ថ្វីបើគោលនយោបាយនេះមានបំណងទូលំទូលាយក្តី ធនាគារពិភពលោករក្សាសិទ្ធិ ស្ថិតក្នុងកាលៈទេសៈលើកលែង ក្នុងការផ្សព្វផ្សាយព័ត៌មានជាក់លាក់ដែលមាននៅក្នុងបញ្ជីរាយនាមករណីលើកលែង រឹតដើម្បីហាមឃាត់ក្នុងការទទួលបានព័ត៌មានដែលជាធម្មតាធនាគារពិភពលោកផ្សព្វផ្សាយ (ដូចដែលបានពន្យល់នៅក្នុងភាគី ទី២ ផ្នែក ខ និង គ នៃគោលនយោបាយនេះ)។

ក. ករណីលើកលែង

៧. ធនាគារពិភពលោកមិនផ្តល់ព័ត៌មានដែលការផ្សព្វផ្សាយនោះ អាចបណ្តាលឱ្យមានផលប៉ះពាល់ដល់ភាគី ឬអត្ថប្រយោជន៍ជាក់លាក់ណាមួយ។ ដូច្នេះ ធនាគារពិភពលោក មិនផ្តល់ឯកសារនានាដែលមាន ឬសំដៅលើ ព័ត៌មានដែលស្ថិតនៅក្នុងកថាខណ្ឌទី៨ ដល់ ១៧ នោះទេ[២]។

៨. ***ព័ត៌មានបុគ្គល*** គោលការណ៍បុគ្គលិករបស់ធនាគារពិភពលោក តំរូវឱ្យធនាគារបង្កើត និងរក្សាសុវត្ថិភាពសមស្របនានាដើម្បីគោរពដល់ភាពឯកជនផ្ទាល់ខ្លួនរបស់បុគ្គលិក និងការពារភាពសម្ងាត់នៃព័ត៌មានបុគ្គលរបស់បុគ្គលិក។ ដូច្នេះធនាគារពិភព-លោកមិនផ្តល់ព័ត៌មានដូចខាងក្រោម លើកលែងតែក្នុងវិសាលភាពជាពិសេសណាមួយដែលអនុញ្ញាតដោយច្បាប់បុគ្គលិក[៣]។

(ក) ព័ត៌មានបុគ្គល រួមមានឯកសារកត់ត្រាបុគ្គលរបស់បុគ្គលិក ព័ត៌មានអំពីវេជ្ជសាស្ត្រ និងការប្រាស្រ័យទាក់ទងជាលក្ខណៈបុគ្គល (រួមមាន សារអេឡិចត្រូនិក) របស់បុគ្គលនានាដូចខាងក្រោម និងក្រុមគ្រួសាររបស់ពួកគេ:

---

[២] នៅក្នុងគោលនយោបាយនេះ ព័ត៌មានដែលឋិតនៅក្នុងករណីលើកលែង ក៏ត្រូវបាននិយាយសំដៅទៅលើ "ព័ត៌មានហាមឃាត់" ផងដែរ។

[៣] "ច្បាប់បុគ្គលិក" សំដៅទៅលើច្បាប់ដែលចែងនៅក្នុងស្បៃវែកាំណែនាំស្តីអំពីបុគ្គលិកផ្នែកទី២ ដែលពិភាក្សាអំពីកាតព្វកិច្ចទូទៅរបស់ធនាគារពិភពលោកទាក់ទងទៅនឹងបុគ្គលិក។

នាយកប្រតិបត្តិ អនុប្រធាន ឬស្តីទី និងទីប្រឹក្សាជាន់ខ្ពស់ ប្រធានធនាគារពិភពលោក មន្ត្រីរបស់ធនាគារ ដទៃៗ ទៀត និងបុគ្គលិករបស់ធនាគារ ។

(ខ) ព័ត៌មានដែលទាក់ទងទៅនឹងការតែងតាំងបុគ្គលិក និងដំណើរការជ្រើសរើស

(គ) ព័ត៌មានទាក់ទងទៅនឹងរបាយការណ៍នៃយន្តការដោះស្រាយជំលោះផ្ទៃក្នុងរបស់ធនាគារពិភពលោក ។

(ឃ) ព័ត៌មានទាក់ទងទៅនឹងការស៊ើបអង្កេតលើការចោទប្រកាន់ដោយគ្មានភស្តុតាងចំពោះបុគ្គលិកដែលបានប្រព្រឹត្ត ខុស និងជំលោះផលប្រយោជន៍បុគ្គល ។

៩. ***ការប្រាស្រ័យទាក់ទងនៅក្នុងការិយាល័យរបស់នាយកប្រតិបត្តិ*** ធនាគារពិភពលោក មិនផ្តល់នូវព័ត៌មាន:

(ក) ការប្រាស្រ័យទាក់ទងនៅក្នុងនិងរវាងការិយាល័យរបស់នាយកប្រតិបត្តិផ្ទាល់ខ្លួន ។

(ខ) ការប្រាស្រ័យទាក់ទងរវាងការិយាល័យរបស់នាយកប្រតិបត្តិផ្ទាល់ខ្លួន និងប្រទេសជាសមាជិក ឬប្រទេសនានា ដែលពួកគេតំណាង ។

(គ) ការប្រាស្រ័យទាក់ទងរវាងការិយាល័យរបស់នាយកប្រតិបត្តិផ្ទាល់ខ្លួន និងភាគីទីបី ។

១០.***គណៈកម្មាធិការក្រមសីលធម៌*** ធនាគារពិភពលោកមិនផ្តល់នូវរបាយការណ៍របស់គណៈកម្មាធិការក្រមសីលធម៌សម្រាប់មន្ត្រីរបស់ក្រុមប្រឹក្សាភិបាលនោះទេ (លុះណាតែមានការសម្រេចពីនាយកប្រតិបត្តិឱ្យផ្សព្វផ្សាយព័ត៌មានបែបនេះ) ។

១១.***ឯកសិទ្ធិរបស់ស្ថាក្តីអតិថិជន*** ធនាគារពិភពលោកមិនផ្តល់នូវព័ត៌មានអាស្រ័យលើឯកសិទ្ធិនៃស្ថាក្តីអតិថិជន រួមមាន ក្នុងចំណោមព័ត៌មានដទៃផ្សេងទៀត សារគមនាគមន៍ដែលត្រូវបានផ្តល់ដោយ និងីទទួលដោយអគ្គស្ថាក្តី ស្ថាក្តីនៅក្នុង ធនាគារពិភព-លោក និងទីប្រឹក្សាច្បាប់ដទៃផ្សេងទៀត ។

១២. ***សន្តិសុខ និងសុវត្ថិភាព*** ធនាគារពិភពលោកមិនផ្តល់នូវ :

(ក) ព័ត៌មានណាដែលផ្សព្វផ្សាយទៅ ប៉ះពាល់ដល់សន្តិសុខរបស់បុគ្គលិកធនាគារពិភពលោក និងក្រុមគ្រួសាររបស់ពួកគេ អ្នកម៉ៅការ បុគ្គលដទៃទៀត និងទ្រព្យសម្បត្តិរបស់ធនាគារពិភពលោក ។

(ខ) ព័ត៌មានអំពីការរៀបចំភស្តុភារនិងដឹកជញ្ជូនដែលទាក់ទងទៅនឹងការដឹកជញ្ជូនទ្រព្យសម្បត្តិ និងឯកសារនានារបស់ធនាគារពិភពលោក និងការដឹកជញ្ជូនទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់បុគ្គលិក ។

(គ) ព័ត៌មានដែលផ្សព្វផ្សាយទៅទំនងជាធ្វើឱ្យគ្រោះថ្នាក់អាយុជីវិត សុខភាព ឬសុវត្ថិភាពរបស់បុគ្គលណាមួយ ឬដល់បរិស្ថាន ។

១៣. ***ព័ត៌មានដែលហាមឃាត់ក្រោមរបបផ្សព្វផ្សាយដោយឡែក និងព័ត៌មានស៊ើបអង្កេតដទៃទៀត*** ធនាគារពិភពលោកមិនផ្តល់ព័ត៌មានដែលព័ត៌មានទាំងនោះត្រូវបានហាមឃាត់ក្រោមរបបផ្សព្វផ្សាយដោយឡែករបស់ (ក) ក្រុមវាយតំលៃឯករាជ្យ (IEG)[៤] ក្រុមអធិការកិច្ច (IP)[៥] នាយកដ្ឋានសុក្រិតភាព (INT)[៦] និងដំណើរការដាក់ទណ្ឌកម្មរបស់ធនាគារពិភពលោក[៧] ធនាគារពិភពលោកក៏មិនផ្តល់ផងដែរនូវការទទួលបានពត៌មានដទៃទៀតដែលនឹងប៉ះពាល់ដល់ការ ស៊ើបអង្កេតដែលមិនបានលើកឡើងនៅក្រោមរបបផ្សព្វផ្សាយដោយឡែកនេះ។

១៤. ***ព័ត៌មានដែលផ្តល់ដោយប្រទេសជាសមាជិក រីភាគីទីបីជាលក្ខណៈសម្ងាត់ ។ ធនាគារពិភពលោកមានកាតព្វកិច្ចក្នុងការការពារព័ត៌មានដែលខ្លួនទទួលបានជាលក្ខណៈសម្ងាត់ ។*** ដូច្នេះ ធនាគារពិភពលោកមិនផ្តល់នូវពត៌មានដែលផ្តល់ឱ្យដោយប្រទេសជាសមាជិកណាមួយ ឬភាគីទីបីណាមួយដែលយល់ថាជាព័ត៌មានសម្ងាត់ ដោយគ្មានការអនុញ្ញាតជាពិសេស របស់ប្រទេសជាសមាជិក ឬភាគីទីបី[៨] ។

១៥. ***កិច្ចការរដ្ឋបាលរួម*** ធនាគារពិភពលោកមិនផ្តល់ព័ត៌មានដែលទាក់ទងទៅនឹងកិច្ចការរដ្ឋបាលរួម របស់ធនាគារពិភពលោករួមមាន ក៏ប៉ុន្តែមិនកំណត់ទេ ការចំណាយរួម លទ្ធកម្ម អចលនទ្រព្យ និងសកម្មភាពដទៃផ្សេងទៀត[៩] ។

---

[៤] សូមមើលគោលនយោបាយរបស់ក្រុមវាយតំលៃឯករាជ្យ IEG ។

[៥] សូមមើលសេចក្តីសម្រេចលេខ IBRD 93-10 លេខ IDA 93-6 ខែកញ្ញា ឆ្នាំ១៩៩៣ (សេចក្តីសម្រេចចិត្ត) ក្នុងការបង្កើតក្រុមអធិការកិច្ច និងសេចក្តីបំភ្លឺបន្តបន្ទាប់លើសេចក្តីសម្រេចចិត្តនោះ (ដូចជាការត្រួតពិនិត្យមើលឡើងវិញលើសេចក្តីសម្រេចចិត្តក្នុងការបង្កើតក្រុមអធិការកិច្ច:សេចក្តីបំភ្លឺឆ្នាំ១៩៩៦ អំពីទិដ្ឋភាពជាក់លាក់នៃក្រុមអធិការកិច្ច និងសេចក្តីបំភ្លឺឆ្នាំ១៩៩៥ នៃការត្រួតពិនិត្យមើលឡើងវិញលើកទី២ របស់ក្រុមអធិការកិច្ចនៃធនាគារពិភពលោក) ឯកសារទាំងអស់នេះអាចរកមើលបាននៅលើវែបសាយតាមអាសយដ្ឋាន Inspection Panel ។

[៦] ក្រុមនេះរួមមាន ព័ត៌មានដែលប្រមូលបាន ទទួលបាន ឬបង្កើតដោយ INT ក្នុងទំនាក់ទំនងជាមួយការសាកសួរ ការស៊ើបអង្កេត ការធ្វើសវនកម្ម ឬការត្រួតពិនិត្យមើលឡើងវិញរបស់ INT លើផ្នែកដទៃផ្សេងទៀត កម្មវិធី ផលិតផល ឬចិន្តផល ព្រមទាំងព័ត៌មានដទៃផ្សេងទៀតដែលទទួលបាន ប្រមូលបានឬបង្កើតដោយ INT ដោយសម្ងាត់ ។

[៧] ដំណើរការនេះរួមមានព័ត៌មានដែលការផ្សព្វផ្សាយរបស់វាត្រូវបានហាមប្រាមនៅក្រោមលក្ខន្តិក:ដាក់ទណ្ឌកម្ម នីតិវិធីដាក់ទណ្ឌកម្ម ។

[៨] នៅពេលប្រទេសជាសមាជិកមួយ ឬភាគីទីបីណាមួយផ្តល់ព័ត៌មានអំពីហិរញ្ញវត្ថុ ពាណិជ្ជកម្ម កម្មសិទ្ធិករ ឬព័ត៌មានដែលមិនមែនជាសាធារណៈដទៃផ្សេងទៀតមកឱ្យធនាគារពិភពលោក ដោយដឹងថាព័ត៌មានទាំងនោះ នឹងមិនត្រូវបានផ្សព្វផ្សាយ នោះធនាគារពិភពលោកចាត់ទុកព័ត៌មានទាំងនេះជាសម្ងាត់ ។ ឯកសារនេះរួមមាន ព័ត៌មានទិន្នន័យ របាយការណ៍ និងការវិភាគ (រួមទាំងសម្បត្តិនៃចំណែកភាគហ៊ុន មុខតំណែង និងព័ត៌មានអំពីការប្រតិបត្តិ) សេចក្តីសម្រេច និងលទ្ធផលការងារដទៃទៀតដែលបង្កើតជាលទ្ធផលនៃ ឬឆ្លើយតបទៅនឹងព័ត៌មានសម្ងាត់ដែលទទួលបានពីប្រទេសជាសមាជិក ឬភាគីទីបី ។ ឯកសារនានាដែលរៀបចំដោយធនាគារពិភពលោកជាសេវាកម្មបង់ថ្លៃ (រួមមាន កិច្ចព្រមព្រៀងច្បាប់ដែលទាក់ទង) អាចផ្សព្វផ្សាយជាសាធារណៈតែបន្ទាប់ពីមានការផ្តល់សិទ្ធិពីប្រទេសជាសមាជិក (ឬភាគីទីបីដទៃទៀត) ដែលពាក់ព័ន្ធបានយល់ព្រមជាលាយលក្ខអក្សរដើម្បីឱ្យផ្សព្វផ្សាយ (សូមមើលកថាខណ្ឌទី២០ (ង)) ។ សំភារៈដែលរក្សាដោយធនាគារពិភពលោកដែលរក្សាសិទ្ធិដោយភាគីដទៃទៀតអាចត្រូវត្រួតពិនិត្យមើលឡើងវិញ ក៏ប៉ុន្តែ ការថតចំលង ឬការចែកចាយសំភារៈទាំងនេះត្រូវបានកំហិតដោយគោរពទៅលើសិទ្ធិនៃការរក្សាសិទ្ធិ។ សូមមើលការពិភាក្សាពាក់ព័ន្ធផងដែរនៅក្នុងកំណត់ត្រាបន្ថែមលេខ១១ ។

[៩] កិច្ចការរដ្ឋបាលរួម រួមមានប្រាក់សោធន និងផែនការអត្ថប្រយោជន៍នៃការចូលនិវត្តន៍ដទៃផ្សេងទៀតរបស់ក្រុមធនាគារពិភពលោក ដែលអភិបាលកិច្ចដោយគណៈកម្មាធិការហិរញ្ញវត្ថុសោធន និងគណៈកម្មាធិការរដ្ឋបាលអត្ថប្រយោជន៍សោធន ។

១៦. ***ព័ត៌មានទាក់ទងទៅនឹងការពិចារណា*** ធនាគារពិភពលោកដូចជាស្ថាប័ន ឬក្រុមផ្សេងៗទៀតដែរ ត្រូវការចាំបាច់នូវពេលវេលាសម្រាប់ពិចារណា និងពិភាក្សាក្រៅពីការពិនិត្យពិច័យជាសាធារណៈ។ វាជាទូទៅដំណើរការទៅបានតាមរយៈការស្រុះស្រួលមតិគ្នា និងវាត្រូវការចាំបាច់នូវឱកាសសម្រាប់អភិវឌ្ឍន្នូវការស្រុះស្រួលមតិគ្នានេះ។ នៅក្នុងកំឡុងពេលដែលដំណើរការនេះ ប្រព្រឹត្តទៅ និងយកមកពិចារណា ធាតុចូលរបស់ភាគីពាក់ព័ន្ធជាច្រើន ក៏ប៉ុន្តែវាត្រូវតែរក្សានូវសុច្ចរិតភាពនៃដំណើរពិចារណាតាមរយៈការសម្របសម្រួល និងការចាត់វិធានការណ៍ការពារ ការផ្លាស់ប្តូរគំនិតដោយសេរី និងដោយស្មោះត្រង់។ ដូច្នេះ នៅខណៈដែលធនាគារពិភពលោកមានផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីសម្រេចចិត្ត លទ្ធផល និងកិច្ចព្រមព្រៀងដែលកើតចេញពីដំណើរគិតពិចារណារបស់ខ្លួននេះ ធនាគារពិភពលោកនឹងមិនផ្តល់ព័ត៌មានដែលមានចែងដូចខាងក្រោម[10] :

(ក) ព័ត៌មាន (រួមមាន សារអេឡិចត្រូនិក កំណត់ត្រា សំបុត្រ អនុស្សរណៈ របាយការណ៍ពង្រាង ឬឯកសារដទៃផ្សេងទៀត) ដែលបានរៀបចំឡើងសម្រាប់ ឬផ្លាស់ប្តូរក្នុងកំឡុងដំណើរការនៃការពិចារណាជាមួយប្រទេសជាសមាជិកនានា ឬអង្គភាពដទៃផ្សេងទៀតដែលធនាគារពិភពលោកធ្វើកិច្ចសហប្រតិបត្តិជាមួយ[11]។

(ខ) ព័ត៌មាន (រួមមាន សារអេឡិចត្រូនិក កំណត់ត្រា សំបុត្រ អនុស្សរណៈ របាយការណ៍ពង្រាង ឬឯកសារដទៃផ្សេងទៀត) ដែលរៀបចំសម្រាប់ ឬផ្លាស់ប្តូរគ្នាក្នុងកំឡុងដំណើរការនៃការពិចារណា ឬពិភាក្សាផ្ទៃក្នុងផ្ទាល់ខ្លួន រួមទាំងឯកសារ នានាខាងក្រោមដែលទាក់ទងទៅនឹងការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល :

(១) កំណត់ហេតុទាំងស្រុងនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងកិច្ចប្រជុំរបស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល និងអនុស្សរណៈរបស់ប្រធានដែលអមទៅដោយឯកសាររបស់ក្រុមប្រឹក្សាភិបាល។

(២) សេចក្តីថ្លែងការរបស់នាយកប្រតិបត្តិ និងបុគ្គលិកនៅក្នុងបរិបទនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ឬកិច្ចប្រជុំគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល។

---

[10] ព័ត៌មានទាក់ទងទៅនឹងការពិចារណា ឬការពិភាក្សាជាក់លាក់អាចប្រកាសជាផ្លូវការ និងផ្សព្វផ្សាយជាចុងក្រោយ ដូចដែលបានបញ្ជាក់នៅក្នុងភាគ ៤ ផ្នែក គ នៃគោល-នយោបាយនេះ។

[11] ព័ត៌មាននេះរួមមានការសាកល្បងបន្ទាន់លើវិស័យហិរញ្ញវត្ថុ ឯកសារជំនួយស្នារតីបន្ទាប់ពីមានការវាយតំលៃលើវិស័យហិរញ្ញវត្ថុដែលគាំទ្រមូលនិធិដោយធនាគារពិភពលោក ក្រោមកម្មវិធីវាយតំលៃវិស័យហិរញ្ញវត្ថុ (FSAP) របាយការណ៍នេះចេញបន្ទាប់ពីការវាយតំលៃរបស់ធនាគារពិភពលោកលើសមត្ថភាពគ្រប់គ្រងបំណុលរបស់រដ្ឋាភិបាល របាយការណ៍ផ្តល់យោបល់បច្ចេកទេសដទៃទៀតដែលស្នើសុំដោយបណ្តាប្រទេសជាសមាជិកពីរតនាគាររបស់ធនាគារពិភពលោក ឯកសារពិភាក្សាដែលទាក់ទងទៅនឹងការបំពេញបន្ថែមរបស់ IDA ការបែងចែកប្រទេសដែលមាន IDA និងការពិភាក្សាជាមួយម្ចាស់ជំនួយទាក់ទងទៅនឹងមូលនិធិមរតក។ ប្រសិនបើប្រទេសជាសមាជិកមួយ ឬភាគីទីបីណាមួយមិនបានចាត់ចំណាត់ថ្នាក់ព័ត៌មានដែលបានផ្តល់ទៅឱ្យធនាគារពិភពលោក និងតាមការសន្និដ្ឋានរបស់ធនាគារពិភពលោក គឺប្រទេសជាសមាជិក ឬភាគីទីបីដែលពាក់ព័ន្ធនោះ មិនបានផ្សព្វផ្សាយព័ត៌មានទាំងនេះជាសាធារណៈទេ បន្ទាប់មកព័ត៌មានទាំងនេះត្រូវបានចាត់ទុកថាជាប្រភេទព័ត៌មានដែលត្រូវត្រួតពិចារណាក្រោមកថាខណ្ឌទី១៦នៃគោលនយោបាយនេះ និងត្រូវបានចាត់ចំណាត់ថ្នាក់ដោយអង្គភាពរបស់ធនាគារអ្នកទទួលដោយអនុលោមទៅតាម AMS 6.21A គោលនយោបាយបែងចែកចំណាត់ថ្នាក់ព័ត៌មាននិងត្រួតពិនិត្យ ដូចដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌទី២០(ឃ)និងកថាខណ្ឌទី៣០នៃគោលនយោបាយនេះ។ ប្រសិនបើធនាគារពិភពលោកជឿថា ព័ត៌មានបែបនេះត្រូវបានប្រគល់ឱ្យដោយប្រទេសជាសមាជិកឬភាគីទីបី (ច្បាស់លាស់ ឬមិនច្បាស់លាស់) ជាលក្ខណៈសម្ងាត់ នោះព័ត៌មានទាំងនេះត្រូវបានចាត់ជាចំណាត់ថ្នាក់ជាបន្តបន្ទាប់ ហើយនឹងត្រូវបានហាមប្រាមមិនឱ្យផ្សព្វផ្សាយដោយអនុលោមទៅតាមកថាខណ្ឌទី១៤ នៃគោលនយោបាយនេះ។

(៣) របាយការណ៍ជូនក្រុមប្រឹក្សាភិបាលពីគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល (ក្រដាសពណ៌បៃតង) ប្រសិនបើគេរំពឹងថានឹងមានកិច្ចពិភាក្សារបស់ក្រុមប្រឹក្សាភិបាលជាបន្តបន្ទាប់[12] ។

(៤) ការប្រាស្រ័យទាក់ទងនឹងអនុស្សរណៈដែលបង្កើតដំបូងគេនៅក្នុងការិយាល័យរបស់នាយកប្រតិបត្តិដែលទាក់ទងទៅនឹងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលឬរបាយការណ៍របស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល ។

(៥) អនុស្សរណៈផ្សេងៗទៀតឬកំណត់ត្រាក្រៅផ្លូវការដែលបានចែកជូនដល់ក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល[13] ។

(គ) ស្ថិតិដែលរៀបចំ ឬការវិភាគដែលធ្វើឡើងជាពិសេសដើម្បីផ្តល់ព័ត៌មានសម្រាប់ដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តផ្ទៃក្នុងរបស់ធនាគារពិភពលោក (ដូចជាការវិភាគលើតំលៃឥណទានរបស់ប្រទេស ចំណាត់ថ្នាក់ឥណទាន និងហានិភ័យរបាយការណ៍នានាដែលគាំទ្រដល់គោលនយោបាយប្រចាំប្រទេស និងការវាយតំលៃស្ថាប័ន (CPIA) សម្រាប់អ្នកខ្ចីរបស់ IBRD និង IDA និងចំណាត់ថ្នាក់ CPIA សម្រាប់អ្នកខ្ចីរបស់ IBRD) ។

(ឃ) របាយការណ៍សវនកម្មដែលរៀបចំឡើងដោយអនុអង្គភាពសវនកម្មផ្ទៃក្នុងលើកលែងរបាយការណ៍បញ្ចប់ប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពប្រចាំត្រីមាស ។

១៧. ***ព័ត៌មានហិរញ្ញវត្ថុ*** ធនាគារពិភពលោកមិនផ្តល់នូវព័ត៌មានហិរញ្ញវត្ថុដូចខាងក្រោម :[14]

(ក) ការប៉ាន់ស្មានកម្ចីក្នុងពេលអនាគតដោយ IBRD វិភាគទានដោយម្ចាស់ជំនួយនីមួយៗសម្រាប់ IDA ការព្យាករណ៍ហិរញ្ញវត្ថុនិងការវាយតំលៃឥណទាន និងទិន្នន័យស្តីពីវិនិយោគទុនកិច្ចសន្យាការពារវិនិយោគទុន ការសុំខ្ចី និងប្រតិបត្តិការគ្រប់គ្រងសាច់ប្រាក់[15] ដែលបង្កើតដោយ ឬសម្រាប់ប្រតិបត្តិរតនាគារនៃធនាគារពិភពលោក សម្រាប់អង្គភាពរបស់ក្រុមធនាគារពិភពលោកនិងភាគីដទៃទៀត ។

(ខ) ឯកសារនានា ការវិភាគ លិខិតឆ្លើយឆ្លង ឬព័ត៌មានដទៃផ្សេងទៀតដែលត្រូវបានប្រើប្រាស់ ឬផលិតដើម្បីបំពេញប្រតិបត្តិការហិរញ្ញវត្ថុ និងថវិកា ឬដើម្បីគាំទ្រដល់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុខាងក្នុងនិងខាងក្រៅ ។

---

[12] ក៏ប៉ុន្តែ ប្រសិនបើគ្មានកិច្ចប្រជុំក្រុមប្រឹក្សាភិបាលជាបន្តបន្ទាប់នោះទេ ធនាគារពិភពលោកផ្សព្វផ្សាយអោយសាធារណៈជនបានដឹងអំពីរបាយការណ៍ដែលដាក់ជូនក្រុមប្រឹក្សាភិបាលពីគណៈកម្មាធិការរបស់ខ្លួនដោយលុបចោលនូវព័ត៌មានដែលទាក់ទង នឹងការសំរេចចិត្ត (ផ្នែកនៃសេចក្តីសង្ខេបនៅលើក្រដាសពណ៌បៃតង) ។
ព័ត៌មានហិរញ្ញវត្ថុជាក់លាក់អាចប្រកាសជាផ្លូវការឺផ្សព្វផ្សាយនៅពេលចុងក្រោយ ដូចដែលបានបញ្ជាក់នៅក្នុងភាគីទី៤ផ្នែកគនៃគោលនយោបាយនេះ ។

[13] ព័ត៌មាននេះគឺជាក្រុមវិសភាគមួយនៃឯកសារនានាដែលរួមមានកំណត់ត្រាព័ត៌មាន ឯកសារសង្ខេបបច្ចេកទេស បទបង្ហាញជា ដែលបំពេញបន្ថែមលើឯកសាររបស់ក្រុមប្រឹក្សាភិបាល បទបង្ហាញនានាដែលដាក់ជូនគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល និងឯកសាររដ្ឋបាល (ដូចជាសេចក្តីជូនដំណឹងអំពីកិច្ចប្រជុំ) ដែលមិនត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការពិគ្រោះយោបល់ ឬធ្វើការសម្រេចចិត្តក៏ប៉ុន្តែត្រូវបានប្រើប្រាស់ជាពិសេសសម្រាប់ក្នុងគោលបំណងផ្តល់ព័ត៌មាន ឬគោលបំណងរដ្ឋបាល ។

[14] ព័ត៌មានហិរញ្ញវត្ថុជាក់លាក់អាចប្រកាសជាផ្លូវការ ឬផ្សព្វផ្សាយនៅពេលចុងក្រោយ ដូចដែលបានបញ្ជាក់នៅក្នុងភាគីទី៤ផ្នែកគនៃគោលនយោបាយនេះ ។

[15] ព័ត៌មាននេះរួមមាន ចំណែកនៃភាគហ៊ុន តួនាទី និងព័ត៌មានអំពីការប្រតិបត្តិសម្រាប់អង្គភាពនានារបស់ក្រុមធនាគារពិភពលោកនិងភាគីដទៃទៀត ។

(គ) សេចក្តីលំអិតអំពីប្រតិបត្តិការនីមួយៗក្រោមកម្ចីនិងមូលនិធិមរតក ព័ត៌មានទាក់ទងនឹងចំនួនលុយ ដែលអ្នក ខ្ចី មិនទាន់បានសងឬចំណាត់វិធានការមុនប្រាក់កម្ចីនានាត្រូវបានដាក់ចូលនៅក្នុងលក្ខខណ្ឌមិនគិតបន្ថែម[16] ។

(ឃ) ព័ត៌មានទាក់ទងទៅនឹងធនាគារពិភពលោក ឬទាក់ទងនឹងវិក័យបត្ររបស់អង្គភាពនៃក្រុមធនាគារពិភពលោក ប្រទេសជាសមាជិក អតិថិជន ម្ចាស់ជំនួយ អ្នកទទួល ឬអ្នកលក់ រួមទាំងអ្នកឯកទេសផងដែរ ។

ខ. បុព្វសិទ្ធិរបស់ធនាគារពិភពលោកក្នុងការផ្សព្វផ្សាយព័ត៌មានហាមឃាត់

១៨. ធនាគារពិភពលោករក្សាសិទ្ធិក្នុងការផ្សព្វផ្សាយ ក្រោមកាលៈទេសៈលើកលែង ព័ត៌មានរដ្ឋបាលរួមជាក់លាក់ (កថាខណ្ឌ ទី១៥) ព័ត៌មានទាក់ទងនៅការពិភាក្សា ឬពិចារណា (កថាខណ្ឌទី១៦) និងព័ត៌មានហិរញ្ញវត្ថុ (កថាខណ្ឌទី១៧ (ក) (ខ) និង(គ)) ដែលត្រូវបានហាមប្រាមក្រោមករណីលើកលែង ប្រសិនបើធនាគារពិភពលោកកំណត់ថា អត្ថប្រយោជន៍រួមនៃការ ផ្សព្វផ្សាយព័ត៌មានទាំងនេះសំខាន់ជាងផលប៉ះពាល់លើអត្ថប្រយោជន៍ដែលការពារដោយករណីលើកលែង ។

ក្នុងការប្រើប្រាស់បុព្វសិទ្ធិ នេះ :

(ក) ការផ្សព្វផ្សាយឯកសាររបស់ក្រុមប្រឹក្សាភិបាល ឬឯកសារកត់ត្រារបស់ក្រុមប្រឹក្សាភិបាល[17] ត្រូវបានចាត់ចូលក្នុងចំណាត់ថ្នាក់ "សម្ងាត់" ឬ "សម្ងាត់បំផុត" ទាមទារឱ្យមានការអនុម័តពីក្រុមប្រឹក្សាភិបាល ។

(ខ) ការផ្សព្វផ្សាយពត៌មានដែលផ្តល់ឱ្យធនាគារពិភពលោកដោយប្រទេសជាសមាជិក ឬភាគីទីបីជាលក្ខណៈសម្ងាត់ទាមទារនូវការយល់ព្រមជាលាយលក្ខអក្សរពីប្រទេសជាសមាជិក ឬភាគីទីបីដែលពាក់ព័ន្ធ ។

(គ) ការផ្សព្វផ្សាយព័ត៌មានហាមឃាត់ដទៃទៀតត្រូវឱ្យមានការអនុម័តពីគណៈកម្មាធិការផ្តល់ព័ត៌មានរបស់ធនាគារពិភពលោក (សូមមើលភាគទី៤ ផ្នែក (ង) នៃគោលនយោបាយនេះ) ។

---

[16] ឧទាហរណ៍ ធនាគារពិភពលោកមិនផ្សព្វផ្សាយព័ត៌មានទាក់ទងទៅនឹងតំលៃនៃការបង់ប្រាក់ទៅឱ្យ និងឈ្មោះនៃអ្នកឯកទេស។ ក៏ប៉ុន្តែ ធនាគារពិភពលោកធ្វើតាមទំលាប់ផ្សព្វផ្សាយរបាយការណ៍ប្រចាំខែស្តីពីប្រាក់កម្ចីនិងឥណទាន និងប្រាក់កម្ចីនីមួយៗ ឥណទាន និងឯកសារទាក់ទងទៅនឹងមូលនិធិមរតក ដូចជាហិរញ្ញប្បទាន កម្ចី ឥណទានអភិវឌ្ឍ ជំនួយបច្ចេកទេសសម្រាប់ការអភិវឌ្ឍ និងកិច្ចព្រមព្រៀងអំពីតំរោង កិច្ចព្រមព្រៀងអំពីការធានា កិច្ចព្រមព្រៀងរដ្ឋបាលនិងជំនួយបច្ចេកទេសវិកិច្ច ព្រមព្រៀងមូលនិធិមរតក។ ក្រៅពីនេះធនាគារពិភពលោក ផ្សព្វផ្សាយឱ្យសាធារណជន ដឹងអំពីរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មប្រចាំឆ្នាំរបស់អ្នកខ្ចី សម្រាប់ប្រតិបត្តិការផ្តល់កម្ចីលើវិនិយោគទុនដែលបានចេញលិខិតអញ្ជើញឱ្យមកធ្វើការចរចានៅថ្ងៃរីក្រោយថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១០ (សូមមើល OP/BP ១០.0២ ការគ្រប់គ្រងហិរញ្ញវត្ថុ) ។

[17] សម្រាប់គោលបំណងនៃគោលនយោបាយនេះ "ឯកសាររបស់ក្រុមប្រឹក្សាភិបាល" សំដៅលើឯកសារនានាដែលត្រូវបានរៀបចំឡើងជាពិសេសដោយបុគ្គលិកសម្រាប់ (ក) ការពិភាក្សា ឬពិចារណា (ការសំរេចចិត្ត)ដោយក្រុមប្រឹក្សាភិបាល (ខ)ការពិភាក្សាដោយគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល ឬ(គ)ព័ត៌មាននៃក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល។ សម្រាប់គោលបំណងនៃគោលនយោបាយនេះ "ឯកសារកត់ត្រារបស់ក្រុមប្រឹក្សាភិបាល" សំដៅលើឯកសារ កត់ត្រានានារបស់ក្រុមប្រឹក្សាភិបាលរឺកិច្ចពិភាក្សារបស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល ដូចជា កំណត់ហេតុទាំងស្រុង កំណត់ហេតុ សេចក្តីថ្លែងការណ៍របស់នាយកប្រតិបត្តិ របាយការណ៍សង្ខេបរបស់ប្រធាន និងសេចក្តីសង្ខេបអំពីការពិភាក្សា។ មិនមែនឯកសារទាំងអស់នេះត្រូវបានរៀបចំឡើងបន្ទាប់ពីគ្រប់កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាលនោះទេ ។

គ. បុព្វសិទ្ធិរបស់ធនាគារពិភពលោកចំពោះការហាមប្រាមលើការផ្សព្វផ្សាយព័ត៌មាន

១៩. ធនាគារពិភពលោកក៏រក្សាសិទ្ធិផងដែរមិនផ្សព្វផ្សាយព័ត៌មាន ក្រោមកាលៈទេសៈពិសេស ដែលធ្លាប់ផ្សាយដូចសព្វដង ប្រសិនបើរកឃើញថាការផ្សព្វផ្សាយនេះ វាទំនងជានឹងបណ្តាលឱ្យមានផលប៉ះពាល់ដល់អត្ថប្រយោជន៍នៃការផ្សព្វផ្សាយនេះ។ បុព្វសិទ្ធិនេះអាចត្រូវបានប្រើប្រាស់តែ:

(ក) ក្រុមប្រឹក្សាភិបាលដោយគោរពទៅតាមឯកសារកត់ត្រារបស់ក្រុមប្រឹក្សាភិបាល

(ខ) អនុប្រធានពាក់ព័ន្ធដោយគោរពទៅតាមឯកសាររបស់ក្រុមប្រឹក្សាភិបាលនិង

(គ) នាយកពាក់ព័ន្ធដោយគោរពទៅតាមព័ត៌មានផ្សេងទៀត។

III- ព័ត៌មានទាក់ទងទៅនឹងប្រទេសជាសមាជិក និងតាគីជនៃទៀត

២០.ធនាគារពិភពលោកប្រកាន់យកវិធីសាស្ត្រដូចខាងក្រោមដើម្បីផ្សព្វផ្សាយព័ត៌មានទាក់ទងទៅនឹងប្រទេសជាសមាជិក/អ្នកខ្ចី :

(ក) ***ឯកសារប្រតិបត្តិសម្រាប់ប្រទេសដែលរៀបចំឡើងដោយធនាគារពិភពលោកដែលជាទម្លាប់ត្រូវបានពិភាក្សាជាមួយប្រទេសជាសមាជិក/អ្នកខ្ចី*** (ឧទាហរណ៍ យុទ្ធសាស្ត្រជំនួយប្រចាំប្រទេស ឯកសារវាយតំលៃគំរោង របាយ-ការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ការងារតាមវិស័យ)។ មុននឹងរៀបចំបញ្ចប់ឯកសារនេះ ធនាគារពិភពលោកស្នើសុំឱ្យប្រទេសជាសមាជិក/អ្នកខ្ចីដែលពាក់ព័ន្ធកំណត់រកឱ្យឃើញថា តើឯកសារនោះមានព័ត៌មានសម្ងាត់ណាមួយទាក់ទងទៅនឹងប្រទេសជាសមាជិក ឬអ្នកខ្ចីដែរឬទេ ឬព័ត៌មានដែលការផ្សព្វផ្សាយរបស់វាអាចមានផលប៉ះពាល់អវិជ្ជមានទៅលើទំនាក់ទំនងរវាងធនាគារពិភពលោក និងប្រទេសជាសមាជិកនោះ។ ធនាគារពិភពលោកដោយពិចារណាទៅលើហេតុផលសមស្រប ធ្វើការកែតម្រូវលើឯកសារទាំងនោះ ដើម្បីឆ្លើយតបទៅនឹងបញ្ហានៃកង្វល់របស់ប្រទេសជាសមាជិក ឬអ្នកខ្ចី។ ឯកសារជំនួយស្មារតីនៃបេសកកម្មប្រតិបត្តិនានា អាចត្រូវបានផ្សព្វផ្សាយជាសាធារណៈ ប្រសិនបើ ទាំងធនាគារពិភពលោកនិងប្រទេសជាសមាជិក ឬអ្នកខ្ចីយល់ព្រម។

(ខ) ***ឯកសារសម្រាប់ប្រទេសដែលបានរៀបចំឡើងដោយធនាគារពិភពលោកដែលមិនមែនជាទម្លាប់ត្រូវបានពិភាក្សាជាមួយប្រទេសជាសមាជិក*** (ដូចជា ឯកសារស្រាវជ្រាវនិងឯកសារពាក់ព័ន្ធនឹងចំណេះដឹង)។ នាយកធនាគារ-ពិភពលោកដែលពាក់ព័ន្ធ អាចពិគ្រោះយោបល់ជាមួយប្រទេសជាសមាជិកពាក់ព័ន្ធ ប្រសិនបើ នាយកនោះជឿជាក់ថាឯកសារនេះមានព័ត៌មានសម្ងាត់ទាក់ទងទៅនឹងប្រទេសជាសមាជិក ឬព័ត៌មានដែលការផ្សព្វផ្សាយរបស់វាមានផលប៉ះពាល់អវិជ្ជមានលើទំនាក់ទំនងរវាងធនាគារពិភពលោកនិងប្រទេសជាសមាជិក។ ធនាគារពិភពលោក

ដោយពិចារណាទៅលើហេតុផលសមស្រប ធ្វើការកែតម្រូវលើឯកសារនោះ ដើម្បីឆ្លើយតបទៅនឹងបញ្ហានៃកង្វល់របស់ប្រទេសជាសមាជិក។

(គ) ***ឯកសារនានាដែលបានរៀបចំឡើង វិផ្តល់សិទ្ធិអោយដោយប្រទេសជាសមាជិកវីអ្នកខ្ចីដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈក្នុងលក្ខខណ្ឌសំរាប់ធ្វើពាណិជ្ជកម្មជាមួយធនាគារពិភពលោក*** ប្រទេសជាសមាជិក ឬអ្នកខ្ចីផ្តល់នូវឯកសារប្រភេទនេះដល់ធនាគារពិភពលោកដោយយល់ឃើញថា ធនាគារពិភពលោកនឹងផ្សព្វផ្សាយឯកសារទាំងនេះឱ្យសាធារណជនបានដឹង[១៨]។

(ឃ) ***ឯកសារដទៃទៀតដែលបានរៀបចំឡើងដោយប្រទេសជាសមាជិក ឬអ្នកខ្ចីដែលកាន់កាប់ដោយធនាគារពិភពលោក*** ប្រទេសនានាជាញឹកញាប់ផ្តល់ឱ្យធនាគារពិភពលោកនូវឯកសារ ឬព័ត៌មានដែលមិនស្ថិតនៅក្នុងប្រភេទណាមួយខាងលើ (ឧទាហរណ៍ បរិបទម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេស បញ្ហាអភិបាលកិច្ច ឬការវិភាគផ្តោតលើវិស័យ ឬផ្តោតលើស្ថាប័ន)។ប្រសិនបើប្រទេសជាសមាជិក ឬអ្នកខ្ចីរៀបចំចាត់ជាចំណាត់ថ្នាក់នូវព័ត៌មានដែលហាមឃាត់មិនឱ្យសាធារណជនមើល នោះធនាគារពិភពលោកមិនផ្សព្វផ្សាយព័ត៌មានទាំងនោះដោយគ្មានការយល់ព្រមជាលាយលក្ខអក្សរពីប្រទេសជាសមាជិក ឬអ្នកខ្ចីនោះទេ។ ជាធម្មតា ធនាគារពិភពលោកណែនាំឱ្យទៅស្នើរសុំព័ត៌មានទាំងនោះពីប្រទេសជាសមាជិក ឬអ្នកខ្ចី។ ប្រសិនបើប្រទេសជាសមាជិក ឬអ្នកខ្ចីមិនរៀបចំជាចំណាត់ថ្នាក់នូវពត៌មានទៅតាមប្រភេទនោះទេ ហើយប្រសិនបើតាមការយល់ដឹងរបស់ធនាគារពិភពលោក ព័ត៌មាននោះមិនទាន់បានផ្សព្វផ្សាយជាសាធារណៈដោយប្រទេសជាសមាជិក ឬអ្នកខ្ចីនោះទេ នោះអង្គភាពធនាគារដែលជាអ្នកទទួល

---

[១៨] ឧទាហរណ៍នៃឯកសារទាំងនេះ : (ក)ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (រួមទាំង PRSPs បណ្តោះអាសន្ន និងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំរបស់ PRSP) (ខ)លិខិតគោលនយោបាយអភិវឌ្ឍន៍ (សូមមើល OP/BP 8.60 គោលនយោបាយកម្ចីសំរាប់ការអភិវឌ្ឍ) (គ)ការវាយតំលៃលើវិធានការការពារសុវត្ថិភាព និងផែនការដែលទាក់ទងទៅនឹងបរិស្ថាន ការតាំងទីលំនៅឡើងវិញ និងជនជាតិដើមភាគតិច (សូមមើល OP/BP 4.01 ការវាយតំលៃលើបរិស្ថាន OP/BP 4.10 ជនជាតិដើមភាគតិច OP/BP 4.12 ការតាំងទីលំនៅឡើងវិញដោយបង្ខំ) (ឃ)របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មហើយសំរាប់គំរោងនានា (រឹក្នុងករណី លើកលែង ឯកសារសង្ខេប) ដែលបានចេញលិខិតអញ្ជើញអោយមកធ្វើការចរចានៅរីក្រោយថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១០ (សូមមើល OP/BP 10.02 ការគ្រប់គ្រងហិរញ្ញវត្ថុ) និង(ង)ផែនការលទ្ធកម្ម (សូមមើលគោលការណ៍ណែនាំ : លទ្ធកម្មក្រោមកម្ចីរបស់; IBRD និងឥណទានរបស់ IDA និងគោលការណ៍ណែនាំ : ការជ្រើសរើសនិងការជួលអ្នកឯកទេសដោយអ្នកខ្ចីរបស់ធនាគារពិភពលោក)។

ចាត់ទុកថា ព័ត៌មាននោះគឺជាប្រភេទព័ត៌មានដែលស្ថិតនៅក្នុងការពិចារណា[19] ហើយចាត់ចំណាត់ថ្នាក់ព័ត៌មាននេះ ដោយអនុលោម ទៅតាម AMS 6.21A គោលនយោបាយចាត់ចំណាត់ថ្នាក់ និងត្រួតពិនិត្យព័ត៌មាន ។

(ង) ***ឯកសារដែលរៀបចំឡើងដោយធនាគារពិភពលោកសម្រាប់សេវាកម្មបង់ថ្លៃ*** ធនាគារពិភពលោកផ្សព្វផ្សាយព័ត៌មាននេះដល់សាធារណជនឱ្យបានដឹង (រួមទាំងកិច្ចព្រមព្រៀងច្បាប់ដែលពាក់ព័ន្ធ) នៅក្រោយពេលដែលមានការអនុញ្ញាតពីប្រទេសជាសមាជិក (ឬភាគីទីបីដទៃផ្សេងទៀត) ដែលពាក់ព័ន្ធយល់ព្រមជាលាយលក្ខអក្សរឱ្យផ្សព្វផ្សាយពត៌មាននេះប៉ុណ្ណោះ ។

២១. ***ឯកសារដែលរៀបចំឡើងរួមគ្នាជាមួយដៃគូ*** ធនាគារពិភពលោកផ្សព្វផ្សាយឱ្យសាធារណជនដឹងអំពីឯកសារចុងក្រោយដែលខ្លួនបានរៀបចំរួមគ្នាមួយដៃគូបន្ទាប់ពីឈានដល់កិច្ចព្រមព្រៀងលើការផ្សព្វផ្សាយព័ត៌មាននេះជាមួយភាគីដែលពាក់ព័ន្ធ[20] ។

IV- និដ្ឋភាពនៃការអនុវត្តគោលនយោបាយនេះ

ក. ការទទួលបានព័ត៌មាន

២២. ***ការផ្សព្វផ្សាយបែបទប់ស្កាត់មុន*** ធនាគារពិភពលោកតាមទំលាប់ផ្សព្វផ្សាយឯកសារជាច្រើនតាមរយៈវេបសាយសាធារណៈរបស់ខ្លួនដែលមានអាសយដ្ឋាន www.worldbank.org នៅពេលដែលឯកសារទាំងនេះត្រូវបានបញ្ចប់ការត្រួតពិនិត្យ ។ ក្រោមគោលនយោបាយនេះ ធនាគារពិភពលោកបង្កើនជាពិសេសនូវបរិមាណព័ត៌មានដែលខ្លួនផ្សព្វផ្សាយទៅឱ្យសាធារណជនដឹងជាពិសេស ព័ត៌មានទាក់ទងទៅនឹងគម្រោងនានាក្រោមការអនុវត្ត ទាក់ទងទៅនឹងចំណាត់វិធានការរបស់ក្រុមប្រឹក្សា នៃនាយកប្រតិបត្តិ ។

---

[19] ប្រសិនបើ ធនាគារពិភពលោកកំណត់ថាពត៌មាននោះត្រូវបានផ្តល់អោយដោយប្រទេសជាសមាជិកឬភាគីទីបីដាលក្នុណៈសំងាត់ នោះព័ត៌មាននោះត្រូវបានត្រូវបាន ហាមប្រាមនៅក្រោមកថាខណ្ឌទី១៤នៃគោលនយោបាយនេះ និងត្រូវបានចាត់ជាចំណាត់ថ្នាក់ទុកជាឯកសារសំងាត់ ។

[20] មុន នឹងចាប់ផ្តើមការងារបែបនេះ បុគ្គលិកធនាគារពិភពលោកពន្យល់អំពីគោលនយោបាយទទួលបានព័ត៌មានរបស់ធនាគារពិភពលោក ដល់ដៃគូសក្តានុពលនិង ទទួលបាននូវការយល់ព្រមពីដៃគូសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានរួមនេះ ។ ឯកសារនានាដែលបានរៀបចំឡើង រួមគ្នាជាមួយដៃគូមិនត្រូវឱ្យសាធារ-ណជនដឹងទេ ប្រសិនបើព័ត៌មានទាំងនេះរួមមាន ឬផ្អែកលើព័ត៌មានដែលត្រូវបានហាមប្រាមក្រោមភាគ២ ផ្នែកកនិងគនៃគោលនយោបាយនេះ ។ សម្រាប់គោលបំណងនៃខចែងក្នុងគោលនយោបាយនេះ អង្គភាពរបស់ក្រុមធនាគារពិភពលោកដទៃ។ទៀតត្រូវបានចាត់ទុកថាជាដៃគូ ឯកសារដែលបានរៀបចំឡើងរួមគ្នាជាមួយអង្គភាពរបស់ក្រុមធនាគារពិភពលោក អាចត្រូវបានផ្សព្វផ្សាយជាសាធារណៈ ប្រសិនបើ ការផ្សព្វផ្សាយទាំងនេះស្របជាមួយនឹងគោលនយោបាយនៃការផ្សព្វផ្សាយរបស់ពួកគេ ។

២៣. ***របាយការណ៍របស់ក្រុមប្រឹក្សាភិបាល*** ឯកសាររបស់ក្រុមប្រឹក្សាភិបាល និងឯកសារកត់ត្រារបស់ក្រុមប្រឹក្សាភិបាល ដែលតាមទម្លាប់ ធនាគារពិភពលោកចុះផ្សាយនៅលើវេបសាយសាធារណៈរបស់ខ្លួននៅឯកិច្ចប្រជុំពិសេស។ ការពិភាក្សាមួយចំនួនរបស់ក្រុមប្រឹក្សាភិបាលអាចពាក់ព័ន្ធទៅនឹងបញ្ហានានាដែលស្ថិតនៅក្រោមករណីលើកលែងក្នុងគោលនយោបាយនេះ។ នៅក្នុងករណីបែបនេះឯកសារកត់ត្រាពាក់ព័ន្ធរបស់ក្រុមប្រឹក្សាភិបាលត្រូវបានចាត់ចំណាត់ថ្នាក់ជា "សម្ងាត់" និង "សម្ងាត់បំផុត" ហើយមិនត្រូវបានផ្សព្វផ្សាយទេលុះណាតែឯកសារទាំងនេះ ទទួលបានសិទ្ធិគ្រប់គ្រាន់សម្រាប់ការផ្សព្វផ្សាយជាផ្លូវការ ក្រោមតារាងពេលវេលានៃការផ្សព្វផ្សាយជាផ្លូវការដែលមានចែងនៅក្នុងកថាខណ្ឌ ៣៣ នៃគោលនយោបាយនេះ។

(ក) ឯកសារកំណត់ត្រារបស់ក្រុមប្រឹក្សាភិបាលខាងក្រោមបានរៀបចំឡើងនៅ ឬក្រោយថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១០ ត្រូវបានផ្សព្វផ្សាយនៅចុងបញ្ចប់នៃដំណើរការសំរេចរបស់ក្រុមប្រឹក្សាភិបាល :

(១) កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល[២១]

(២) កំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល

(៣) របាយការណ៍របស់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការនៃកិច្ចប្រជុំទាំងមូល។

(៤) សេចក្តីសង្ខេបអំពីកិច្ចពិភាក្សា (ទាក់ទងទៅនឹងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល)។

(៥) របាយការណ៍ដាក់ជូនក្រុមប្រឹក្សាភិបាលដោយគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល (ក្រដាសពណ៌បៃតង) ដោយលុបព័ត៌មានដែលទាក់ទងទៅនឹងការសំរេចចិត្តចេញ (ផ្នែកនៃសេចក្តីសង្ខេបលើក្រដាសពណ៌បៃតង) ប្រសិនបើ មិនមានកិច្ចពិភាក្សារបស់ក្រុមប្រឹក្សាភិបាលបន្តបន្ទាប់ទេនោះ។

(៦) របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល។

(ខ) ឯកសាររបស់ក្រុមប្រឹក្សាភិបាលដែលបានចែកចាយសម្រាប់កិច្ចពិភាក្សា ឬពិចារណា (ការសំរេចចិត្ត) ដោយក្រុមប្រឹក្សាភិបាលជាធម្មតាត្រូវបានផ្សព្វផ្សាយនៅចុងបញ្ចប់នៃដំណើរការសំរេចចិត្តរបស់ក្រុមប្រឹក្សាភិបាលនៅពេលដែលឯកសារទាំងនោះត្រូវបានពិនិត្យរួចរាល់។ ក៏ប៉ុន្តែឯកសាររបស់ក្រុមប្រឹក្សាភិបាលខាងក្រោមដែលការរៀបចំនោះអាចមានការពាក់ព័ន្ធកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ក្រុមសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀតត្រូវបានបិទផ្សាយមុនកិច្ចពិភាក្សារបស់ក្រុមប្រឹក្សាភិបាល :

---

[២១] កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលដែលបានចងក្រងឡើងនៅក្រោយថ្ងៃទី០១ ខែ មេសា ឆ្នាំ២០០៥ ត្រូវបានផ្សព្វផ្សាយជាសាធារណៈរួចហើយ។ កំណត់ ហេតុប្រជុំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដែលបានរៀបចំឡើងមុនថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ សូមមើលកថាខណ្ឌទី៣៣។

(១) ឯកសារគោលនយោបាយប្រតិបត្តិ និងឯកសារយុទ្ធសាស្ត្រតាមវិស័យដែលត្រូវបានរៀបចំឡើងក្រោយដំណើរនៃកិច្ចពិគ្រោះយោបល់សាធារណៈ ប្រសិនបើនាយកប្រតិបត្តិបានត្រួតពិនិត្យមើលឡើងវិញរួចរាល់ហើយលើឯកសារពង្រាងនោះ[២២]។

(២) ឯកសារយុទ្ធសាស្ត្រជំនួយប្រចាំប្រទេស ឯកសារវាយតំលៃគម្រោង និងឯកសារកម្មវិធី ប្រសិនបើប្រទេសជាសមាជិកយល់ព្រមឱ្យផ្សព្វផ្សាយមុន។

(គ) ឯកសាររបស់ក្រុមប្រឹក្សាភិបាលដែលបានចែកចាយសម្រាប់ធ្វើការពិភាក្សាដោយគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាលត្រូវបានផ្សព្វផ្សាយនៅចុងបញ្ចប់នៃការសំរេចចិត្តរបស់គណៈកម្មាធិការ ប្រសិនបើមិនមានកិច្ចពិភាក្សាក្រុមប្រឹក្សាភិបាលបន្ទាប់ទៀតទេនោះ។

(ឃ) ឯកសាររបស់ក្រុមប្រឹក្សាភិបាលដែលត្រូវបានចែកជូនដល់នាយប្រតិបត្តិសម្រាប់ជាព័ត៌មានត្រូវបានផ្សព្វផ្សាយនៅចំពេលចែកចាយ។

២៤. ***ព័ត៌មានតាមសំណើ*** ព័ត៌មានដែលអាចផ្សព្វផ្សាយបានក្រោមគោលនយោបាយនេះ និងមិនស្ថិតនៅលើវែបសាយសាធារណៈរបស់ធនាគារពិភពលោក អាចស្នើសុំបាន (ផ្អែកលើកថាខណ្ឌទី២៦)។ សំណើបែបនេះ អាចត្រូវដាក់បញ្ជូនសុំការអនុម័តជាលាយលក្ខអក្សរតាមរយៈមធ្យោបាយអេឡិចត្រូនិក ប្រៃសណីយ៍ ទូរសារ។ សំណើទាំងនេះ គួរតែបញ្ជាក់ ជាមួយនឹងហេតុផលសមស្រប ព័ត៌មានដែលកំពុងស្នើសុំ ដើម្បីឱ្យធនាគារពិភពលោករៀបចំព័ត៌មាននេះនៅក្នុងពេលវេលាមួយដ៏សមស្រប។ ប្រសិនបើគេត្រូវការឯកសារជាក់លាក់មួយ នោះគេគួរតែបញ្ជាក់ឱ្យបានច្បាស់លាស់ បើអាចធ្វើបាន សូមបញ្ជាក់កាលបរិច្ឆេទ និងចំណងជើងឯកសារនោះផង។ ការដាក់ស្នើសុំតាមប្រព័ន្ធអេឡិចត្រូនិកគួរតែត្រូវបានបញ្ជូនមកតាមរយៈវែបសាយរបស់ធនាគារពិភពលោកដែលមានអាសយដ្ឋាន www.worldbank.org/wbaccess ។ ការស្នើសុំទាំងនេះក៏អាចត្រូវបានធ្វើឡើងផងដែរដោយមកកាន់មណ្ឌលព័ត៌មានដោយផ្ទាល់នៅក្នុងទីក្រុងវ៉ាស៊ីនតោនឌីស៊ី ឬមជ្ឈមណ្ឌលព័ត៌មានសាធារណៈ ដែលមានទីតាំងនៅក្នុងប្រទេសជាសមាជិកទាំងអស់។

២៥. ***រយៈពេលសម្រាប់ឆ្លើយតបទៅនឹងសំណើ*** ធនាគារពិភពលោកទទួលសំណើជាលាយលក្ខអក្សរដែលស្នើសុំព័ត៌មានក្នុងរយៈពេល ៥ថ្ងៃនៃថ្ងៃធ្វើការ ហើយព្យាយាមផ្តល់ចំលើយឱ្យបានល្អឿនក្នុងរយៈពេល ២០ថ្ងៃនៃថ្ងៃធ្វើការ។ ធនាគារអាចត្រូវការពេលវេលាបន្ថែមចាំបាច់ក្នុងកាលៈទេសៈពិសេសណាមួយ រួមមាន ឧទាហរណ៍ សំណើសុំទាំងឡាយណាដែលមានភាព

[២២] ប្រសិនបើឯកសារពង្រាងនោះមិនទាន់ត្រូវបានត្រួតពិនិត្យមើលឡើងវិញដោយនាយកប្រតិបត្តិនោះទេ ឯកសារនេះនៅតែអាចផ្សព្វផ្សាយឱ្យសាធារណជនដឹងបាន ក្នុងរយៈពេលយ៉ាងហោចណាស់ ២សប្តាហ៍មុនកិច្ចពិភាក្សារបស់ក្រុមប្រឹក្សាភិបាល ប្រសិនបើ ក្រុមប្រឹក្សាភិបាលអនុម័តឱ្យផ្សព្វផ្សាយ។

ស្នុត្រស្នាញ ឬសំណើដែលមានចំនួនច្រើន ឬសំណើដែលទាមទារឱ្យធ្វើការត្រួតពិនិត្យមើលឡើងវិញ តាមរយៈ ឬការពិគ្រោះយោបល់ជាមួយអង្គភាពនៅខាងក្នុងធនាគារ ភាគីនៅខាងក្រៅ គណៈកម្មាធិការផ្តល់ព័ត៌មាន ឬក្រុមប្រឹក្សាភិបាល។

២៦. ***សំណើសុំដែលមិនសមហេតុផលឬមិនច្បាស់លាស់*** ធនាគារពិភពលោករក្សាសិទ្ធិក្នុងការបដិសេធលើសំណើសុំដែលមិនសមហេតុផលឬមិនច្បាស់លាស់ រួមមាន សំណើសុំច្រើន សំណើសុំលក្ខណៈទូលាយ និងសំណើសុំណាដែលតម្រូវឱ្យធនាគារពិភពលោកបង្កើត អភិវឌ្ឍ ឬប្រមែប្រមូលព័ត៌មាន ឬទិន្នន័យដែលមិនមាន ឬមិនអាចរកបាននៅក្នុងប្រព័ន្ធគ្រប់គ្រងឯកសាររបស់ធនាគារពិភពលោក[២៣]។ ធនាគារពិភពលោកជាធម្មតាសំរេចចិត្តបដិសេធសំណើសុំដែលមិនសមហេតុផល ឬមិនច្បាស់លាស់ក្នុងពេលវេលាមួយដែលមានចែងនៅក្នុងកថាខណ្ឌទី២៥នៃគោលនយោបាយនេះ។

២៧. ***ថ្លៃសេវាកម្ម*** ព័ត៌មានប្រតិបត្តិភាគច្រើន ជាទ្បើងទាត់ត្រូវបានចុះផ្សាយនៅលើវេបសាយសាធារណៈរបស់ធនាគារពិភពលោក ហើយអាចរកថតចំលងទុកចេញពីវេបសាយបានដោយឥតគិតថ្លៃ។ ចំពោះសំណើសុំព័ត៌មានណាដែលមិនបានផ្សព្វផ្សាយជាទ្បើងទាត់ទេនោះ ធនាគារពិភពលោកអាចកំណត់យកថ្លៃសេវាកម្មដែលសមហេតុផលសម្រាប់ការផ្តល់ព័ត៌មានជា ឌីជីថល ឬ ជាសន្លឹកជាពិសេស សម្រាប់សំណើសុំទាំងឡាយណាដែលមានលក្ខណៈស្នុត្រស្នាញ ឬត្រូវចំណាយពេលវេលាច្រើន។ ការបោះពុម្ពផ្សាយមូលដ្ឋានទិន្នន័យឯកទេសមួយចំនួន និងព័ត៌មានទាក់ទងចំពោះដឹងដទៃៗទ្បើត (រួមមាន សេវាកម្មជាវ) អាច ជាវបានតាមរយៈការិយាល័យអ្នកបោះពុម្ពផ្សាយរបស់ធនាគារពិភពលោក។ អត្ថបទទាំងស្រុងនៅក្នុងស្បៀវភៅដែលបានបោះពុម្ពផ្សាយដោយការិយាល័យអ្នកបោះពុម្ពផ្សាយនេះ អាចមើលឃើញនិងថតចំលងចេញពីវេបសាយដោយឥតគិតថ្លៃ ឬអាចមើលឃើញនៅលើវេបសាយរបស់ Google Book។ មូលដ្ឋានទិន្នន័យស្ថិតិស្នូលអាចរកមើលបានដោយឥតគិតថ្លៃនៅលើ វេបសាយរបស់ធនាគារពិភពលោក។

ខ. ការចាត់ចំណាត់ថ្នាក់

២៨. ឯកសាររបស់ធនាគារពិភពលោកត្រូវបានចាត់ចូលក្នុងចំណាត់ថ្នាក់មួយក្នុងចំណោមចំណាត់ថ្នាក់៤ ដូចខាងក្រោម: "សាធារណៈ" "សម្រាប់ការប្រើប្រាស់ផ្ទៃការតែប៉ុណ្ណោះ" "សម្ងាត់" ឬ "សម្ងាត់បំផុត"។

---

[២៣] សំណើដែលមិនច្បាស់លាស់រួមមាន (ក)សំណើទាំងឡាយណាដែលមិនផ្តល់នូវព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើឱ្យធនាគារពិភពលោកមានលទ្ធភាពអាចរៀបចំឯកសារដែលស្នើសុំនោះនៅក្នុងប្រព័ន្ធគ្រប់គ្រងឯកសាររបស់ធនាគារពិភពលោក និង ឬ(ខ)សម្រាប់ឯកសារដែលធនាគារពិភពលោកមិនអាចរក្សាទុកនៅក្នុងប្រព័ន្ធគ្រប់គ្រងឯកសាររបស់ធនាគារពិភពលោកក្រោយពីមានការស្វែងរកដោយសមហេតុផលមួយ។

២៩. ***ព័ត៌មានដែលធនាគារពិភពលោកបង្កើត*** អនុលោមទៅតាម AMS 10.11 ការគ្រប់គ្រងឯកសារកត់ត្រា ធនាគារពិភពលោកតម្រូវឱ្យអ្នកដែលបង្កើតឯកសារដំបូងគេដែលបានរៀបចំទុកសម្រាប់ប្រើប្រាស់ផ្លូវការរបស់ធនាគារពិភពលោក រក្សាទុកជាឯកសារនូវឯកសារទាំងនេះនៅក្នុងប្រព័ន្ធគ្រប់គ្រងឯកសាររបស់ធនាគារពិភពលោក។ ព័ត៌មានជាច្រើនដែលបានបង្កើតដោយធនាគារពិភពលោកត្រូវបានប្រកាសឱ្យសាធារណជនដឹង ហើយត្រូវបានចាត់ចូលក្នុងចំណាត់ថ្នាក់ជា "សាធារណៈ"។ ព័ត៌មានដែលស្ថិតនៅក្នុងករណីលើកលែង និងឯកសារដែលមានព័ត៌មានត្រូវបានចាត់ចូលក្នុងចំណាត់ថ្នាក់ "សម្រាប់ប្រើប្រាស់ផ្លូវការតែប៉ុណ្ណោះ" "សម្ងាត់" ឬ "សម្ងាត់បំផុត" ដោយអនុលោមទៅតាម AMS 6.21A គោលនយោបាយចាត់ចំណាត់ថ្នាក់ និងត្រួតពិនិត្យព័ត៌មាន។ ឯកសារព្រាងត្រូវបានចាត់ថា ជាឯកសារដែលត្រូវពិចារណា ឬពិភាក្សា។

៣០. ***ព័ត៌មានដែលធនាគារពិភពលោកទទួល*** ធនាគារពិភពលោកក៏ទាមទារផងដែរថា ប្រទេសជាសមាជិក ឬភាគីទីបីរៀបចំចាត់ចំណាត់ថ្នាក់ព័ត៌មានឱ្យបានសមស្រប នូវរាល់ព័ត៌មានដែលខ្លួនផ្តល់ឱ្យធនាគារពិភពលោក។ ប្រសិនបើ ធនាគារពិភពលោកទទួលបានព័ត៌មានជាសម្ងាត់ពីប្រទេសជាសមាជិកមួយ ឬភាគីទីបីណាមួយ នោះអង្គភាពរបស់ធនាគារពិភពលោក ដែលជា អ្នកទទួលធានាថាព័ត៌មានបែបនេះ (ក) ត្រូវបានចាត់ចំណាត់ថ្នាក់យ៉ាងសមស្របដោយអនុលោមទៅតាមការរំពឹងទុករបស់អ្នកផ្តល់ឱ្យការប្រើប្រាស់កម្រិតនៃការចាត់ចំណាត់ថ្នាក់ព័ត៌មានរបស់ធនាគារពិភពលោក និង (ខ) ត្រូវបានរក្សាទុកនៅក្នុងប្រព័ន្ធគ្រប់គ្រងឯកសាររបស់ធនាគារពិភពលោក ធនាគារពិភពលោកមិនផ្សព្វផ្សាយព័ត៌មានបែបនេះដោយគ្មានការយល់ព្រមជាលាយលក្ខអក្សរពីប្រទេសជាសមាជិក ឬភាគីទីបីដែលពាក់ព័ន្ធនោះទេ។ ប្រសិនបើប្រទេសជាសមាជិក ឬភាគីទីបីខកខានមិនបានចាត់ចែងរៀបចំចាត់ចំណាត់ថ្នាក់ព័ត៌មានទាំងនោះទេ ហើយប្រសិនបើតាមការយល់ដឹងរបស់ធនាគារពិភពលោក ព័ត៌មានទាំងនោះ មិនទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅឡើយដោយប្រទេសជាសមាជិក ឬភាគីទីបីនោះទេ នោះធនាគារពិភពលោកចាត់ទុកព័ត៌មានទាំងនេះជា (ដែលពាក់ព័ន្ធ) ព័ត៌មានទាក់ទងទៅនឹងការពិភាក្សា ឬពិចារណា ឬព័ត៌មានដែលផ្តល់ឱ្យជាលក្ខណៈសម្ងាត់[២៤]

[២៤] អង្គភាពរបស់ធនាគារពិភពលោកដែលជាអ្នកទទួលចាត់ចំណាត់ថ្នាក់ព័ត៌មាននេះដោយអនុលោមទៅតាម AMS 6.21A គោលនយោបាយ ចាត់ចំណាត់ថ្នាក់និងត្រួតពិនិត្យព័ត៌មាន។

គ. ការប្រកាសជាផ្លូវការចំពោះព័ត៌មានដែលផុតកំណត់ជាព័ត៌មានសម្ងាត់

៣១. ធនាគារពិភពលោកប្រកាសជាផ្លូវការនិងផ្សព្វផ្សាយព័ត៌មាន (ជាទ្បើងទាត់នៅលើវេបសាយសាធារណៈរបស់ធនាគារពិភពលោក និងជាការឆ្លើយតបទៅនឹងការស្នើសុំ) ប្រភេទជាក់លាក់នៃព័ត៌មានដែលហាមប្រាម (រួមមានព័ត៌មានដែលរៀបចំ

[២៤] សូមមើលហ្វូតណូតលេខ១១។

ក្រោមគោលនយោបាយផ្សព្វផ្សាយមុនរបស់ធនាគារពិភពលោក) ដោយសារតែភាពរសើបបានថយចុះក្នុងរយៈពេលចុងក្រោយ។ ព័ត៌មានហាមប្រាមមួយចំនួនមិនអាចប្រកាសផ្សព្វផ្សាយជាផ្លូវការបានទេ។

៣២. ***ព័ត៌មានដែលមិនអាចប្រកាសជាផ្លូវការបាន*** ព័ត៌មានដែលត្រូវបានហាមប្រាមមិនអោយផ្សព្វផ្សាយក្រោមករណីលើកលែងដែលបានចែងនៅក្នុងកថាខណ្ឌទី៨ ដល់១៥ និងទី១៧ (ឃ) នៃគោលនយោបាយនេះ (ដូចជា ព័ត៌មានផ្ទាល់ខ្លួន ការប្រាស្រ័យទាក់ទងនៅការិយាល័យរបស់នាយកប្រតិបត្តិ គណៈកម្មាធិការក្រមសីលធម៌ បុព្វសិទ្ធិស្មាក្តីអតិថិជន សន្តិសុខ និងសុវត្ថិភាព ព័ត៌មានដែលបានហាមប្រាមក្រោមរបបផ្សព្វផ្សាយដោយឡែក និងព័ត៌មានស៊ើបអង្កេតដទៃទៀត ព័ត៌មានដែលផ្តល់ដោយប្រទេសជាសមាជិក ឬភាគីទីបីជាសម្ងាត់ កិច្ចការរដ្ឋបាលរួម និងព័ត៌មានទាក់ទងនឹងធនាគារ ឬវិក្កយប័ត្ររបស់អង្គភាពនៃក្រុមធនាគារពិភពលោក ប្រទេសជាសមាជិក អតិថិជន ម្ចាស់ជំនួយ អ្នកទទួល ឬអ្នកទិញ រួមទាំងអ្នកឯកទេស) និងព័ត៌មានបិរញ្ញវត្ថុ និងព័ត៌មានទាក់ទងនឹងការសំរេចចិត្តដែលមាន ឬទាក់ទងទៅនឹងព័ត៌មានបែបនេះ មិនត្រូវបានប្រកាសជាផ្លូវការ ឬផ្សព្វផ្សាយជាសាធារណៈនោះឡើយ។

៣៣. ***ព័ត៌មានដែលអាចប្រកាសជាផ្លូវការបាន*** ឯកសារខាងក្រោមត្រូវបានប្រកាសជាផ្លូវការ និងប្រកាសជាសាធារណៈក្នុងរយៈពេល ៥ ១០ ឬ ២០ឆ្នាំ ក្រោយកាលបរិច្ឆេទនៅលើឯកសារនោះ[២៥] *ប្រសិនបើព័ត៌មានទាំងនោះមិនមានឬមិនសំដៅលើព័ត៌មានដែលមិនអាចប្រកាសជាផ្លូវការ ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី៣២នៃគោលនយោបាយនេះ :*

ក្រោយ ៥ឆ្នាំ

- កំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាលដែលបានរៀបចំឡើងមុនថ្ងៃទី ០១ខែ មេសា ឆ្នាំ២០០៥ ក្រៅពីកំណត់ហេតុនៃផ្នែកប្រតិបត្តិ និងផ្នែកប្រតិបត្តិហាមប្រាម។
- កំណត់ហេតុរបស់កិច្ចប្រជុំគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាលដែលបានរៀបចំឡើងមុនថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ២០១០ ក្រៅពីកំណត់ហេតុនៃផ្នែកប្រតិបត្តិហាមប្រាម។

---

[២៥] ក្នុងការអនុវត្តន៍នូវតារាងពេលវេលានៃការប្រកាសជាផ្លូវការទាំងនេះ កាលបរិច្ឆេទពាក់ព័ន្ធសម្រាប់ឯកសារដែលមិនទាន់បានបោះពុម្ព គឺជាកាលបរិច្ឆេទនៅពេលដែលឯកសារនោះត្រូវបានបង្កើត កាលបរិច្ឆេទពាក់ព័ន្ធសម្រាប់ឯកសារដែលបានបោះពុម្ពហើយ គឺជាកាលបរិច្ឆេទនៃការបោះពុម្ព។ តារាងពេលវេលានៃការប្រកាសជាផ្លូវការ ពិពណ៌នានៅក្នុងផ្នែកនេះត្រូវតែបានអានជារួម ដើម្បីធានាថាឯកសារដែលពាក់ព័ន្ធត្រូវបានប្រកាសជាផ្លូវការដោយសមស្រប។ ឧទាហរណ៍ ទោះបីជាឯកសាររបស់ក្រុមប្រឹក្សាភិបាលដែលស្ថិតក្នុងចំណាត់ថ្នាក់ "សម្រាប់ប្រើប្រាស់ផ្លូវការតែប៉ុណ្ណោះ" អាចត្រូវបានប្រកាសជាផ្លូវការក្រោយ ៥ឆ្នាំ ក៏ដោយ ក៏អនុស្សរណៈរបស់ប្រធាន (ដែលអាចត្រូវបានចាត់ចូលក្នុងជាចំណាត់ថ្នាក់ឯកសាររបស់ក្រុមប្រឹក្សាភិបាល "សម្រាប់ប្រើប្រាស់ផ្លូវការតែប៉ុណ្ណោះ" ត្រូវបានប្រកាសជាផ្លូវការក្រោយរយៈពេល ២០ឆ្នាំ ប៉ុណ្ណោះ)។

- សុន្ទរកថាបិទរបស់ប្រធាន និងរបាយការណ៍សង្ខេបនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលដែលរៀបចំឡើងមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០២ ។
- របាយការណ៍សង្ខេបរបស់គណៈកម្មាធិការនៃកិច្ចប្រជុំទាំងមូលដែលបានរៀបចំឡើងមុនថ្ងៃទី០១ ខែ កក្កដា ឆ្នាំ២០១០ ។
- សេចក្តីសង្ខេបអំពីការពិភាក្សា (ទាក់ទងទៅនឹងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល) ដែលបានរៀបចំឡើងមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ ។
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាលដែលបានរៀបចំឡើងមុនថ្ងៃទី០១ ខែ កក្កដា ឆ្នាំ២០១០ ។
- ឯកសាររបស់ក្រុមប្រឹក្សាភិបាលដែលត្រូវបានរៀបចំឡើងមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ និងត្រូវបានចាត់ចំណាត់ជា "សម្រាប់ប្រើប្រាស់ផ្លូវការប៉ុណ្ណោះ" ។
- ឯកសារចុងក្រោយដែលបានចុះបញ្ជីនៅក្នុងឱបសម្ព័ន្ធនៃគោលនយោបាយនេះដែលត្រូវបានរៀបចំឡើងមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ និងត្រូវបានចាត់ចំណាត់ថ្នាក់ជា "សម្រាប់ប្រើប្រាស់ផ្លូវការប៉ុណ្ណោះ" ។ (ឯកសារព្រាង និងឯកសារទាក់ទងនឹងការសំរេចចិត្តដទៃទៀត ទោះបីជាត្រូវបានចាត់ចំណាត់ថ្នាក់ជា "សម្រាប់ប្រើប្រាស់ផ្លូវការប៉ុណ្ណោះ" ក៏ដោយ ក៏ត្រូវបានចាត់ទុកថាជាព័ត៌មានដែលត្រូវធ្វើការសំរេច និងត្រូវប្រកាសជាផ្លូវការក្នុងរយៈពេល២០ឆ្នាំក្រោយ ។)

ក្រោយ ១០ឆ្នាំ

- កំណត់ហេតុទាំងស្រុងនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនិងកិច្ចប្រជុំរបស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល ។
- សេចក្តីថ្លែងការណ៍របស់នាយកប្រតិបត្តិនិងបុគ្គលិកនៅក្នុងបរិបទនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ឬកិច្ចប្រជុំរបស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល ។
- របាយការណ៍ដាក់ជូនក្រុមប្រឹក្សាភិបាលដោយគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល (ក្រដាសពណ៌បៃតង) ។
- អនុស្សរណៈផ្សេងៗឬកំណត់ត្រាក្រៅផ្លូវការដែលបានចែកជូនដល់ក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល ។

ក្រោយ ២០ឆ្នាំ

- កំណត់ហេតុនៃសម័យប្រជុំប្រតិបត្តិនិងសម័យប្រជុំប្រតិបត្តិសំងាត់របស់ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល ។

- ការប្រាស្រ័យទាក់ទងនឹងអនុស្សរណៈដែលបង្កើតដំបូងនៅក្នុងការិយាល័យរបស់នាយកប្រតិបត្តិទាក់ទងទៅនឹងក្រុមប្រឹក្សាភិបាលឬរបាយការណ៍របស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល។
- ឯកសាររបស់ក្រុមប្រឹក្សាភិបាលដែលត្រូវបានចាត់ចំណាត់ថ្នាក់ជា "សម្ងាត់" "សម្ងាត់បំផុត"។
- អនុស្សរណៈរបស់ប្រធានដែលអមឯកសាររបស់ក្រុមប្រឹក្សាភិបាល។
- ឯកសារចុងក្រោយដែលបានរាយនាមនៅក្នុងឧបសម្ព័ន្ធនៃគោលនយោបាយនេះដែលត្រូវបានរៀបចំឡើងមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ ហើយត្រូវបានចាត់ចំណាត់ថ្នាក់ជា "សម្ងាត់" ឬ "សម្ងាត់បំផុត"។
- ព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានបាមប្រាមក្រោមកថាខណ្ឌទី១៧ (ក) (ខ) និង(គ) លុះណាតែព័ត៌មាននោះទាក់ទងទៅនឹងករណីលើកលែងដែលបានកំណត់នៅក្នុងកថាខណ្ឌទី៨ ដល់១៥ ឬទី១៧(ឃ)នៃគោលនយោបាយនេះ។
- ឯកសារដទៃទៀតដែលមាននៅក្នុងអង្គភាពឯកសាររបស់ធនាគារពិភពលោក លុះណាតែឯកសារនោះទាក់ទងទៅនឹងករណីលើកលែងដែលបានកំណត់នៅក្នុងកថាខណ្ឌទី៨ ដល់១៥ ឬ១៧ (ឃ)នៃគោលនយោបាយនេះ រួមទាំងព័ត៌មានទាក់ទងទៅនឹងការសំរេចចិត្តឬទាក់ទងនឹងហិរញ្ញវត្ថុដែលមានឬដែលសំដៅលើករណីលើកលែងទាំងនោះ។

ឃ. សារអេឡិចត្រូនិក

៣៤. សារអេឡិចត្រូនិកដែលបានក្លាយជាមធ្យោបាយសំខាន់របស់ធនាគារពិភពលោកក្នុងការប្រាស្រ័យទាក់ទង ត្រូវបានចាត់ទុកដូចខាងក្រោម :

(ក) សារអេឡិចត្រូនិកដែលមាន ឬភ្ជាប់ដោយការសំរេចចិត្ត ឬលទ្ធផល ហើយដែលត្រូវបានរក្សានៅក្នុងប្រព័ន្ធគ្រប់គ្រងឯកសាររបស់ធនាគារពិភពលោក ហើយនឹងត្រូវបានចាត់ចំណាត់ថ្នាក់ជា "**សាធារណៈ**" ត្រូវបានប្រកាសជាសាធារណៈ។

(ខ) សារអេឡិចត្រូនិកដែលត្រូវបានរក្សាទុកនៅក្នុងប្រព័ន្ធគ្រប់គ្រងឯកសាររបស់ធនាគារពិភពលោក ក៏ប៉ុន្តែត្រូវបានចាត់ចំណាត់ថ្នាក់ជា "សម្រាប់ប្រើប្រាស់ផ្លូវការប៉ុណ្ណោះ" "**សម្ងាត់**" ឬ "**សម្ងាត់បំផុត**" មិនត្រូវបានផ្សព្វផ្សាយឱ្យដឹងជាសាធារណៈទេ លុះណាតែខ្លឹមសារនៃព័ត៌មាននៅក្នុងសារអេឡិចត្រូនិកនោះ អាចត្រូវបានប្រកាសជាផ្លូវការ ឬផ្សព្វផ្សាយនៅពេលចុងក្រោយ។

(គ) ធនាគារពិភពលោកមិនផ្តល់សារអេឡិចត្រូនិកដែលស្ថិតនៅក្រៅប្រព័ន្ធគ្រប់គ្រងឯកសាររបស់ខ្លួនទេ រួមមានសារអេឡិចត្រូនិកដែលមិនទាក់ទងទៅនឹងកិច្ចការផ្លូវការ ឬ និងសារអេឡិចត្រូនិកដែលមានព័ត៌មានផ្ទាល់ខ្លួន

ឬការប្រាស្រ័យទាក់ទងរបស់បុគ្គលិកធនាគារពិភពលោកនិងមន្ត្រីដទៃផ្សេងទៀត សូមមើល កថាខណ្ឌទី ៨(ក)និង១៦(ក)និង(ខ)នៃគោលនយោបាយនេះ។

៦. គណៈកម្មាធិការផ្តល់ព័ត៌មាន

៣៥. ដើម្បីសម្របសម្រួលដល់ការអនុវត្តគោលនយោបាយនេះ ធនាគារពិភពលោកបានបង្កើតនូវគណៈកម្មាធិការផ្តល់ព័តិមាន (AI committee) ដែលគ្រប់គ្រង និងរាយការណ៍ជូនថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក។ គណៈកម្មាធិការផ្តល់ព័តិមានផ្តល់យោបល់ដល់ថ្នាក់គ្រប់គ្រងអំពីការអនុវត្តគោលនយោបាយនេះ លើបញ្ហាស្មុគ្រស្មាញនានា ត្រួតពិនិត្យមើលសំណើសុំដើម្បីផ្សព្វផ្សាយព័តិមានដែលនៅលើបញ្ជីរាយនាមករណីលើកលែង[២៦] ទទួលបាន និងត្រួតពិនិត្យមើលការប្តឹងឧទ្ធរណ៍ក្រោមគោលនយោបាយនេះ[២៧] បង្កើតសេវាកម្មបង់ថ្លៃនិងបទដ្ឋានសេវាកម្ម និងចេញនូវគោលការណ៍ណែនាំដល់បុគ្គលិកស្តីអំពីការអនុវត្តគោលនយោបាយនេះ។ គណៈកម្មាធិការផ្តល់ព័តិមាន មានសិទ្ធិអំណាចក្នុងការបកស្រាយគោលនយោបាយនេះ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់គោលនយោបាយនេះ និងគាំទ្រ ឬផ្លាស់ប្តូរសេចក្តីសំរេចចិត្តមុនក្នុងការបដិសេធ មិនផ្តល់ព័តិមានដោយមានករណីលើកលែងនៃការសំរេចចិត្តដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារពិភពលោក។

៧. ការប្តឹងឧទ្ធរណ៍

៣៦. អ្នកស្នើសុំដែលត្រូវបានគេបដិសេធមិនផ្តល់ព័តិមានឱ្យដោយធនាគារពិភពលោក អាចប្តឹងឧទ្ធរណ៍បាន ប្រសិនបើ :

(ក) អ្នកស្នើសុំនោះអាចមានលទ្ធភាពបង្កើតករណីឃើញមួយភ្លែតដែលធនាគារពិភពលោកបានរំលោភលើគោលនយោបាយនេះ តាមរយៈការហាមប្រាមដោយមិនសមរម្យ ឬដោយមិនសមហេតុផល មិនផ្តល់ព័តិមានឱ្យដែលវាជាធម្មតាព័តិមាននេះត្រូវបានផ្សព្វផ្សាយក្រោមគោលនយោបាយនេះ ឬ

(ខ) អ្នកស្នើសុំនោះមានលទ្ធភាពអាចបង្កើតទៅជារឿងក្តីផលប្រយោជន៍សាធារណៈ ដើម្បីទាត់ចោលនូវករណីលើកលែងរបស់គោលនយោបាយនេះដែលវិតត្បិតក្នុងការផ្តល់ព័តិមានដែលគេបានស្នើសុំ (កំហិតលើករណីលើកលែងទាំងនោះដែលបានចែងនៅក្នុងកថាខណ្ឌទី១៥ (កិច្ចការរដ្ឋបាលរួម)កថាខណ្ឌទី១៦ (ព័តិមាន

---

[២៦] សូមមើលភាគពីរផ្នែកខនៃគោលនយោបាយនេះសម្រាប់សេចក្តីលំអិតស្តីអំពីបុព្វសិទ្ធិរបស់ធនាគារពិភពលោកក្នុងការផ្សព្វផ្សាយព័តិមានហាមប្រាមក្រោមស្ថានភាព លើកលែង។

[២៧] សូមមើលភាគបួនផ្នែកច នៃគោលនយោបាយនេះស្តីអំពីខចែងទាក់ទងទៅនឹងការប្តឹងឧទ្ធរណ៍។

ទាក់ទងនឹងការពិភាក្សា) និងកថាខណ្ឌទី១៧(ក) (ខ) និង(គ) (ទាក់ទងទៅនឹងព័ត៌មានហិរញ្ញវត្ថុជាក់លាក់)នៃគោលនយោបាយនេះ)។

មូលហេតុដែលមានសម្រាប់អ្នកស្នើសុំដែលប្តឹងឧទ្ធរណ៍ត្រូវបានកំហិតក្នុងការទទួលបាននូវព័ត៌មានដែលបានស្នើសុំ។

៣៧. ***ការប្តឹងឧទ្ធរណ៍លើការបដិសេធដំបូង គណៈកម្មាធិការផ្តល់ព័ត៌មាន*** ការប្តឹងឧទ្ធរណ៍លើការសំរេចចិត្តរបស់ធនាគារពិភពលោកដែលបដិសេធមិនផ្តល់ព័ត៌មានឱ្យត្រូវបានយកមកពិចារណាជាដំបូងដោយគណៈកម្មាធិការផ្តល់ព័ត៌មានរបស់ធនាគារពិភពលោក[២៨]។ សម្រាប់ការប្តឹងឧទ្ធរណ៍ដែលទាក់ទងទៅនឹងរឿងក្តីអត្ថប្រយោជន៍សាធារណៈក្នុងការទាត់ចោលករណីលើកលែងក្នុងគោលនយោបាយនេះ[២៩] ការសំរេចចិត្តរបស់គណៈកម្មាធិការផ្តល់ព័ត៌មាន គឺស្ថិតនៅក្នុងដំណាក់កាលចុងក្រោយ។ គណៈកម្មាធិការផ្តល់ព័ត៌មានអាចសំរេចចិត្តបញ្ជូនបញ្ហាជាក់លាក់មួយទៅឱ្យនាយកគ្រប់គ្រងដែលពាក់ព័ន្ធ ដើម្បីសុំអនុសាសន៍ ដែលគណៈកម្មាធិការផ្តល់ព័ត៌មាននេះពិចារណាលើការសំរេចចិត្តនោះ[៣០]។ ការប្តឹងឧទ្ធរណ៍ចំពោះគណៈកម្មាធិការផ្តល់ព័ត៌មាន ត្រូវតែបានរក្សាទុកជាលាយលក្ខអក្សរក្នុងរយៈពេល៦០ថ្ងៃនៃថ្ងៃប្រតិទិនរបស់ការសំរេចចិត្តដំបូងរបស់ធនាគារពិភពលោក ក្នុងការបដិសេធមិនផ្តល់ព័ត៌មានដែលគេបានស្នើសុំ។ គណៈកម្មាធិការផ្តល់ព័ត៌មាន ប្រឹងប្រែងអស់លទ្ធភាពក្នុងការឈានទៅដល់ការធ្វើសេចក្តីសំរេចចិត្តលើបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល៤៥ថ្ងៃនៃថ្ងៃធ្វើការនៃការទទួលបណ្តឹងឧទ្ធរណ៍ ការពន្យាពេលអាចធ្វើឡើងជាលាយលក្ខអក្សរជូនទៅអ្នកស្នើសុំ។

៣៨. ***ការប្តឹងឧទ្ធរណ៍លើការបដិសេធរបស់គណៈកម្មាធិការផ្តល់ព័ត៌មាន ក្រុមប្រឹក្សាប្តឹងឧទ្ធរណ៍*** ធនាគារពិភពលោកបានបង្កើតក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍ឯករាជ្យមួយ[៣១] ដើម្បីពិចារណាលើបណ្តឹងឧទ្ធរណ៍ដែលចោទប្រកាន់ដោយគ្មានភស្តុតាងថាធនាគារពិភពលោកបានរំលោភលើគោលនយោបាយដោយរឹតត្បិតក្នុងការផ្តល់លទ្ធភាពអោយទទួលបាននូវព័ត៌មានដែលជាធម្មតាព័ត៌មាននេះត្រូវបានផ្សព្វផ្សាយក្រោមគោលនយោបាយនេះ[៣២] ប្រសិនបើគណៈកម្មាធិការផ្តល់ព័ត៌មាននេះគាំទ្រការសំរេចចិត្ត

---

[២៨] ដោយសារតែគណៈកម្មាធិការផ្តល់ព័ត៌មានពុំមានសិទ្ធិអំណាចលើសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាភិបាល នោះការប្តឹងឧទ្ធរណ៍លើសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាភិបាលត្រូវបានទាត់ចោលជាស្វ័យប្រវត្តិ។

[២៩] សូមមើលកថាខណ្ឌ ៣៦(ខ)

[៣០] ករណីនេះអាចរួមមានបណ្តឹងនានានៅពេលដែលគណៈកម្មាធិការផ្តល់ព័ត៌មានបានផ្តល់ភាពចូលដោយផ្ទាល់ទៅក្នុងការសំរេចចិត្តដំបូងក្នុង ការបដិសេធមិនផ្តល់ព័ត៌មាន ឱ្យ។

[៣១] ក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍បានបង្កើតឡើងក្រោមគោលនយោបាយនេះ រួមមានអ្នកជំនាញការមកពីខាងក្រៅចំនួនពីរូបដែលមានជំនាញលើកិច្ចការផ្តល់ព័ត៌មាន។ សមាជិកក្នុងក្រុមត្រូវបានតែងតាំងដោយប្រធានធនាគារពិភពលោក និងយល់ព្រមដោយក្រុមប្រឹក្សាភិបាលនៃនាយកប្រតិបត្តិរបស់ ធនាគារពិភព-លោក។

[៣២] សូមមើលកថាខណ្ឌ៣៦(ក)។

ដំបូងក្នុងការបដិសេធមិនផ្តល់ព័ត៌មាន ក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍មិនពិចារណាលើបណ្តឹងឧទ្ធរណ៍ដែលពាក់ព័ន្ធទៅនឹងសំណើសុំទាត់ចោលករណីលើកលែងរបស់គោលនយោបាយនោះទេ[៣៣] ក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍មានសិទ្ធិអំណាចក្នុងការគាំទ្រ ឬធ្វើសារជាថ្មីលើសេចក្តីសំរេចចិត្តពាក់ព័ន្ធរបស់គណៈកម្មាធិការផ្តល់ព័ត៌មាន ហើយការសំរេចចិត្តរបស់ក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍នៅក្នុងរឿងក្តីបែបនេះគឺជាដំណាក់កាលចុងក្រោយ ។ការប្តឹងឧទ្ធរណ៍លើក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍ត្រូវតែបានរក្សាទុកជាលាយលក្ខអក្សរក្នុងរយៈពេល៦០ថ្ងៃនៃថ្ងៃប្រតិទិន ក្រោយពីការសំរេចចិត្តរបស់គណៈកម្មាធិការផ្តល់ព័ត៌មានដើម្បីគាំទ្រដល់ការសំរេចចិត្តដំបូងរបស់ធនាគារពិភពលោកក្នុងការបដិសេធមិនផ្តល់ព័ត៌មាននោះ។ ក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍ ប្រឹងប្រែងអស់លទ្ធភាពដើម្បីពិចារណាលើបណ្តឹងឧទ្ធរណ៍ទាំងអស់ដែលខ្លួនទទួលបានក្នុងរយៈពេលសមស្របមុនសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍ដែលគ្រោងធ្វើនៅពេលបន្ទាប់ ។

៣៩. ***ការដាក់បញ្ជូនបណ្តឹងឧទ្ធរណ៍*** បណ្តឹងឧទ្ធរណ៍ទាំងអស់ត្រូវតែដាក់បញ្ជូនមកជាលាយលក្ខអក្សរមកកាន់លេខាធិការដ្ឋានផ្តល់ព័ត៌មានក្នុងរយៈពេល៦០ថ្ងៃនៃថ្ងៃប្រតិទិននៃការសំរេចចិត្តក្នុងការបដិសេធក្នុងការផ្តល់ព័ត៌មាន។ បណ្តឹងឧទ្ធរណ៍ដែលទទួលបានក្រោយ៦០ថ្ងៃសំរាប់ការប្តឹងឧទ្ធរណ៍ជាមួយគណៈកម្មាធិការផ្តល់ព័ត៌មាន (ដំណាក់កាលដំបូងទី១នៃបណ្តឹងឧទ្ធរណ៍) និងក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍ (ដំណាក់កាលទី២នៃបណ្តឹងឧទ្ធរណ៍) ត្រូវបានចាត់ទុកថាអស់ពេលវេលា និងមិនត្រូវបានពិចារណា។ បណ្តឹងឧទ្ធរណ៍អាចត្រូវដាក់បញ្ជូនតាមមធ្យោបាយអេឡិចត្រូនិក តាមរយៈវេបសាយរបស់ធនាគារពិភពលោក ដែលមានអាសយដ្ឋាន www.worldbank.org/wbaccess ។ បណ្តឹងឧទ្ធរណ៍ក៏អាចត្រូវបានធ្វើឡើងផងដែរតាមរយៈលិខិតខ្ជឺ។ និងបញ្ជូនតាមរយៈប្រៃសណីយ៍ទៅកាន់លេខាធិការដ្ឋានផ្តល់ព័ត៌មាន ធនាគារពិភពលោក ១៨១៨ H Street NW, វ៉ាស៊ីន តោន ឌីស៊ី ២០៤៣៣ ។ ការប្តឹងឧទ្ធរណ៍គួរតែត្រូវបានបញ្ជូនទៅឱ្យគណៈកម្មាធិការផ្តល់ព័ត៌មានផង (ដំណាក់កាលទី១ នៃបណ្តឹងឧទ្ធរណ៍) និងក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍ផង (ដំណាក់កាលទី២នៃបណ្តឹងឧទ្ធរណ៍សំរាប់បណ្តឹងឧទ្ធរណ៍ទាំងឡាយដែលចោទប្រកាន់ដោយគ្មានភស្តុតាងថាធនាគារពិភពលោកបានរំលោភលើគោលនយោបាយរបស់ខ្លួនដោយរឹតត្បិតមិនត្រឹមត្រូវ ឬមិនសមហេតុផលក្នុងការផ្តល់ព័ត៌មាន) ។ បណ្តឹងឧទ្ធរណ៍ទាំងអស់ត្រូវតែមានដូចខាងក្រោម :

(ក) លេខរឿងក្តីដើមដំបូង ដែលធនាគារពិភពលោកបានឆ្លើយតបទៅនឹងសំណើសុំព័ត៌មាន។

(ខ) សេចក្តីបរិយាយអំពីព័ត៌មានដែលបានស្នើសុំលើកដំបូង និង

---

[៣៣] សូមមើលកថាខណ្ឌ៣៦(ខ) ។

(គ) លិខិតពន្យល់មួយដែលបង្ហាញអំពីការពិតនិងសេចក្តីសំអាងដែលគាំទ្រដល់ការទាមទាររបស់អ្នកស្នើសុំដែល (១) ធនាគារពិភពលោកបានរំលោភលើគោលនយោបាយនេះតាមរយៈការរឹតត្បិតមិនត្រឹមត្រូវ ឬមិនសមរម្យក្នុងការផ្តល់ព័ត៌មានដែលគេបានស្នើសុំ (២) សម្រាប់ហេតុផលផលប្រយោជន៍សាធារណៈ ត្រូវបញ្ជាក់ពីហេតុផលអំពីការទាត់ចោលករណីលើកលែងរបស់គោលនយោបាយនេះ។

៤0. ***សេចក្តីប្រកាសអំពីការសំរេចចិត្ត*** អ្នកស្នើសុំនានាត្រូវបានជូនដំណឹងប្រសិនបើការប្តឹងឧទ្ធរណ៍នោះត្រូវបានទាត់ចោល: (ក) ចំពោះការខកខានមិនបានប្តឹងឧទ្ធរណ៍ក្នុងរយៈពេលកំណត់ (ខ) ចំពោះការខកខានមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ដែល នឹងគាំទ្រឱ្យបានសមហេតុផលលើបណ្តឹងឧទ្ធរណ៍នោះ ឬ (គ) ចំពោះការប្តឹងឧទ្ធណ៍លើបញ្ហាដែលគណៈកម្មាធិការផ្តល់ព័ត៌មាន ឬក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍មិនមានសិទ្ធិអំណាចក្នុងការពិចារណា។ បន្ទាប់ពីគណៈកម្មាធិការផ្តល់ព័ត៌មាន ឬក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍ឈានដល់ធ្វើការសំរេចចិត្តពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍នោះ អ្នកស្នើសុំត្រូវបានជំរាបជូនដំណឹងអំពីការសំរេចចិត្តនេះ។ ប្រសិនបើគណៈកម្មាធិការផ្តល់ព័ត៌មាន ឬក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍គាំទ្រលើការសំរេចចិត្តដំបូងក្នុងការបដិសេធមិនផ្តល់ព័ត៌មានដែលបានស្នើសុំ សេចក្តីជូនដំណឹងនេះត្រូវបញ្ជាក់ឱ្យបានសមហេតុផល។ ប្រសិនបើគណៈកម្មាធិការផ្តល់ព័ត៌មាន ឬក្រុមប្រឹក្សាភិបាលប្តឹងឧទ្ធរណ៍ធ្វើការសំរេចចិត្តឡើងវិញក្នុងការបដិសេធមិនព្រមផ្តល់ព័ត៌មាន អ្នកស្នើសុំត្រូវបានជូនដំណឹងអំពីការសំរេចចិត្តនេះ ហើយត្រូវបានជូនដំណឹងអំពីដំណើរការចំពោះការផ្សព្វផ្សាយព័ត៌មានឱ្យដល់អ្នកស្នើសុំ។

៥១. ឧបសម្ព័ន្ធ

តារាងពេលវេលានៃការប្រកាសជាផ្លូវការសម្រាប់ឯកសារកាលប្បវត្តិជាក់លាក់

ដែលបានបង្កើតឡើងមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០

អនុលោមទៅតាមកថាខណ្ឌទីពាក់ព័ន្ធនៃគោលនយោបាយនេះ ឯកសារចុងក្រោយដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធនេះ (ប្រសិនបើឯកសារទាំងនេះត្រូវបានរៀបចំឡើងមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ និងមិនទាន់បានផ្សព្វផ្សាយជាសាធារណៈ ដោយអនុលោមទៅតាមគោលនយោបាយផ្សព្វផ្សាយមុនរបស់ធនាគារពិភពលោក) អាចត្រូវបានប្រកាសជាផ្លូវការដោយយោងទៅលើតារាងពេលវេលាដូចខាងក្រោម :

(ក) ៥ឆ្នាំក្រោយកាលបរិច្ឆេទនៃឯកសារដែលបានចាត់ចំណាត់ថ្នាក់ជា "សម្រាប់ប្រើប្រាស់ផ្លូវការប៉ុណ្ណោះ" និង

(ខ) ២០ឆ្នាំក្រោយកាលបរិច្ឆេទនៃឯកសារដែលបានចាត់ចំណាត់ថ្នាក់ជា "សម្ងាត់" ឬ "សម្ងាត់បំផុត" ។

ឯកសារទាំងនេះ អាចត្រូវបានប្រកាសជាផ្លូវការប្រសិនបើ ឯកសារទាំងនេះមិនមាន ឬមិនសំដៅទៅលើព័ត៌មានដែលស្ថិតនៅក្នុងករណីលើកលែងណាមួយ ដែលមិនអនុញ្ញាតឱ្យប្រកាសជាផ្លូវការនោះ (សូមមើលកថាខណ្ឌទី៣២នៃគោលនយោបាយនេះ) ។

ក. ឯកសារប្រតិបត្តិដែលបានរៀបចំឡើងដោយធនាគារពិភពលោក

- យុទ្ធសាស្ត្រជំនួយអភិវឌ្ឍន៍ប្រទេស (CAS)
- របាយការណ៍វឌ្ឍនភាពរបស់ CAS
- កំណត់សំគាល់អំពីយុទ្ធសាស្ត្របណ្តោះអាសន្ន
- របាយការណ៍បញ្ចប់អំពី CAS (ដាក់បញ្ចូលជាឧបសម្ព័ន្ធមួយនៅក្នុងលទ្ធផលរបស់ CAS)
- សេចក្តីប្រកាសព័ត៌មានសាធារណៈសម្រាប់ CAS
- លិខិតផ្តល់យោបល់រួមរបស់បុគ្គលិកស្តីពីឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (PRSPs)
- ព្រំដែនកំណត់អំពីហិរញ្ញប្បទានប្រចាំប្រទេស (រួមបញ្ចូលទាំងការវិភាគដែលគាំទ្រដល់ការរៀបចំ)
- របាយការណ៍សេដ្ឋកិច្ចនិងរបាយការណ៍ការងារតាមវិស័យ និងរបាយការណ៍ជំនួយបច្ចេកទេសដែលមិនមែនជាកម្ចី
- ឯកសារបច្ចេកទេសដែលត្រឹមត្រូវដែលគាំទ្រដល់ការរៀបចំគម្រោង
- ឯកសារវាយតំលៃគម្រោង (ពីមុនជារបាយការណ៍វាយតំលៃបុគ្គលិក)
- ឯកសារគម្រោង

- ឯកសារកម្មវិធីសម្រាប់ប្រតិបត្តិការគោលនយោបាយអភិវឌ្ឍន៍ (DPOs)
- ឯកសារហិរញ្ញវត្ថុបន្ថែម (DPOs)
- ឯកសារបញ្ចេញប្រាក់មួយលើកៗ (DPOs)
- សន្ធឹកទិន្នន័យអំពីវិធានការការពាររួម
- របាយការណ៍វាយតំលៃប្រចាំប្រទេសស្តីអំពីការប្រើប្រាស់ប្រព័ន្ធប្រចាំប្រទេស (UCS)
- ការវាយតំលៃគម្រោងសម្រាប់ប្រទេសដែលសាកល្បង UCS
- របាយការណ៍បញ្ចប់ការអនុវត្តនិងរបាយការណ៍លទ្ធផល (ICR)
- លិខិតលុបចោលប្រតិបត្តិការ (NCO) (ពីមុនជាលិខិតបញ្ចប់គម្រោង)
- របាយការណ៍កម្ចីនិងឥណទានប្រចាំខែ
- សេចក្តីសង្ខេបប្រតិបត្តិប្រចាំខែអំពីបណ្តាញផ្តល់កម្ចី (MOS)
- ស្ថានភាពនៃគម្រោងក្នុងប្រតិបត្តិ (SOPE)
- របាយការណ៍ត្រួតពិនិត្យមើលឡើងវិញលើការប្រតិបត្តិផលប័ត្រប្រចាំប្រទេស (CPPRs)
- ឯកសារយុទ្ធសាស្ត្រតាមវិស័យ (SSPs) ឯកសារយុទ្ធសាស្ត្រតាមវិស័យពង្រាង លិខិតទស្សនាទានពង្រាង និងផែនការពិគ្រោះយោបល់ SSP
- គោលនយោបាយប្រតិបត្តិដទៃទៀតទាំងអស់និងឯកសារយុទ្ធសាស្ត្រ
- គោលនយោបាយប្រចាំប្រទេសដែលបង្ហាញជាលេខ និងការកំណត់លំដាប់ជាលេខនៃការវាយតំលៃស្ថាប័នសំរាប់ប្រទេសដែលមានសិទ្ធិទទួលបាននូវហិរញ្ញប្បទាន IDA
- ការកំណត់លំដាប់ជាលេខលើការប្រតិបត្តិប្រចាំប្រទេសរបស់ IDA ដែលបង្ហាញជាតួលេខ (ក្លាយមកពីការកំណត់លំដាប់ថ្នាក់នៃ CPIA)
- សំណើសុំផ្តល់មូលនិធិសម្រាប់សកម្មភាពនានាដែលផ្តល់ហិរញ្ញប្បទានតាមរយៈមូលមរតកដែលគ្រប់គ្រងដោយធនាគារពិភពលោក
- ឯកសារបឋម អំពីការសំរេចចិត្ត និងការបញ្ចប់ ដែលបានរៀបចំឡើងក្រោមគំនិតផ្តួចផ្តើមរបស់ប្រទេសក្រីក្រដែលជាប់បំណុលច្រើន
- ការរួមបញ្ចូលគ្នានៃក្រុមធានាគុណភាព QAG

ខ. ព័ត៌មានហិរញ្ញវត្ថុ

- ឯកសារថវិកាប្រចាំឆ្នាំ

គ. ឯកសារដែលរៀបចំឡើងដោយប្រទេសជាសមាជិក

- ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ
- លិខិតស្តីអំពីគោលនយោបាយអភិវឌ្ឍន៍
- ផែនការលទ្ធកម្មនិងបច្ចុប្បន្នកម្ម

ឃ. រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាឥណ្ឌា

- កម្មវិធីការងាររបស់នាយកប្រតិបត្តិ

សេចក្តីបន្ថែម

ប្រភពព័ត៌មានរបស់ធនាគារពិភពលោក

ខាងក្រោមនេះគឺជាការជ្រើសរើសនូវប្រភពព័ត៌មានរបស់ធនាគារពិភពលោក

ព័ត៌មានទំនាក់ទំនងទូទៅ

ក្រុមធនាគារពិភពលោក

១៨១៨ H Street NW

វ៉ាស៊ីនតោនឌីស៊ី ២០៤៣៣ USA

ទូរស័ព្ទ : ១-២០២-៤៧៣-១០០០

ទូរសារ : ១-២០២-៤៧៧-៦៣៩១

វែបសាយ : http://www.worldbank.org

លទ្ធភាពទទួលបានព័ត៌មាន

វែបសាយ : http://www.worldbank.org/wbaccess

ប្រភពរបស់លោក-អ្នកសម្រាប់ទទួលបាននូវព័ត៌មាន និងប្រភពសំខាន់ៗដទៃទៀតនៃព័ត៌មានរបស់ធនាគារពិភពលោក ។

បណ្ណសារ

វែបសាយ : http://www.worldbank.org/archives

បណ្ណសារទាំងនេះមានព័ត៌មានអំពីការអភិវឌ្ឍទាក់ទងទៅនឹងប្រទេសជាសមាជិករបស់ក្រុមធនាគារពិភពលោកដែលបានចុះកាលបរិច្ឆេទចាប់តាំងពីឆ្នាំ១៩៤៦ រហូតមកដល់បច្ចុប្បន្ន ។ ការប្រមែប្រមូលទុកជាឯកសារនូវព័ត៌មានទាំងនេះ រួមមានឯកសារគម្រោងផ្តល់ប្រាក់កម្ចី ឯកសារប្រចាំប្រទេស របាយការណ៍ សេដ្ឋកិច្ច ការសិក្សាតាមវិស័យ ឯកសារគោលនយោបាយ កិច្ចសំភាសន៍ផ្ទាល់មាត់ក្នុងអតីតកាល ភាពយន្ត វីដេអូ រូបថត ។

សេវាកម្មព័ត៌មានសាធារណៈ

វេបសាយ : http://www.worldbank.org/publicinformation

ទទួលបាននូវព័តិមានសម្រាប់ទាក់ទងសម្រាប់មជ្ឈមណ្ឌលព័តិមានសាធារណៈរបស់ធនាគារពិភពលោកទាំងអស់ ។ ធនាគារពិភពលោកគ្រប់គ្រងសេវាកម្មព័តិមានសាធារណៈនៅក្នុងប្រទេសជិត១00ប្រទេស ហើយផ្តល់នូវលទ្ធភាពទទួលបាននូវព័តិមានដោយផ្ទាល់នៅតាមមជ្ឈមណ្ឌលព័តិមានច្រើនជាង ២៣0 ដោយសហការជាមួយស្ថាប័ននៅតាមប្រទេស និងដៃគូអភិវឌ្ឍន៏ ព្រមទាំងតាមរយៈវេបសាយផ្សេងៗដែលមានជាភាសាអារ៉ាប់ បារាំង ចិនកុកងឺ អេស្ប៉ាញ រុស្សុី និងភាសាដទៃទៀត ។

បណ្ណាល័យរក្សាឯកសារ

វេបសាយ : http://www.worldbank.org/OI.ORKI94LO

ទទួលបាននូវសៀវភៅរាយឈ្មោះនិងអាសយដ្ឋានរបស់បណ្ណាល័យរក្សាឯកសារនាពេលបច្ចុប្បន្ន ។ បណ្ណាល័យរក្សាឯកសាររបស់ធនាគារពិភពលោកស្ថិតនៅក្នុងប្រទេសជាង១00 ហើយបើកជាសាធារណៈ ។ បណ្ណាល័យជាច្រើនត្រូវបានបំពាក់គ្រឿងបរិក្ខាដើម្បីផ្តល់នូវលទ្ធភាពទទួលបានព័តិមានតាមវេបសាយរបស់ធនាគារពិភពលោក មូលដ្ឋានទិន្នន័យ និងឯកសារបោះពុម្ពផ្សាយនានា ចំណែកឯបណ្ណាល័យផ្សេងៗទៀត មានការសំរាំងឯកសារឌីជីថល អំពីសៀវភៅរបស់ធនាគារពិភពលោក ទិន្នានុប្បវត្តិ ឯកសារការងារស្រាវជ្រាវ គោលនយោបាយ និងមូលដ្ឋានទិន្នន័យ ។ នៅក្នុងករណីជាច្រើន សៀវភៅបោះពុម្ពក៏អាចរកបាន ផងដែរ ។

ឯកសារនិងរបាយការណ៏

វេបសាយ : http://www.worldbank.org/documents

ស្វែងរកឯកសាររបស់ធនាគារពិភពលោកនិងរបាយការណ៏ ឬរកមើលប្រភេទឯកសារតាមប្រទេស តាមប្រធានបទ ឬតាមភាសា ។

គម្រោង

វេបសាយ : http://www.worldbank.org/projects

ស្វែងរកព័តិមានអំពីគម្រោងបានច្រើនជាង១0.000គម្រោង ពីឆ្នាំ១៩៤៧ រហូតដល់បច្ចុប្បន្ន សេចក្តីសង្ខេបអំពីការផ្តល់កម្ចីប្រចាំប្រទេស និងឯកសារវិភាគ រង្វាន់ប្រចាំប្រទេសពីខែកក្កដា ឆ្នាំ២000 ដល់បច្ចុប្បន្ន និងឯកសារប្រតិបត្តិ និងឯកគម្រោងរាប់ពាន់ឯកសារទៀត ។

ទិន្នន័យ

វេបសាយ ៖ http://data.worldbank.org

ទទួលបាននូវសូចនាករច្រើនជាង ២.000ពីប្រភពទិន្នន័យរបស់ធនាគារពិភពលោក រួមទាំង សូចនាករអភិវឌ្ឍន៍ពិភពលោកដែលទទួលបានការកោតសរសើរខ្ពស់ ហិរញ្ញវត្ថុអភិវឌ្ឍសកលលោក សូចនាករអភិវឌ្ឍនៅអាហ្វ្រិក និងសំណុំទិន្នន័យដទៃជាច្រើនទៀត។ វេបសាយផ្តុំកទិន្នន័យបង្កលក្ខណៈងាយស្រួល ក្នុងការរកប្រើប្រាស់ និងរៀបចំទិន្នន័យ និងរួមបញ្ចូលនៅចំនុចតភ្ជាប់ទៅកាន់ទិន្នន័យ API របស់ធនាគារពិភពលោក សម្រាប់អ្នកអភិវឌ្ឍន៍។

របាយការណ៍ប្រចាំឆ្នាំ

វេបសាយ ៖ http://www.worldbank.org/annualreport

ទទួលបាននូវរបាយការណ៍ប្រចាំឆ្នាំក្នុងប្រភេទឯកសារជាភីឌីអែហ្វ និងស្វែងរកបណ្តាញផ្សព្វផ្សាយចំរុះនៅលើវេបសាយ ដែលបន្ថែមពីលើឯកសារបោះពុម្ព។ ពិនិត្យមើលរបាយការណ៍ហិរញ្ញវត្ថុបញ្ចប់ និងទិន្នន័យផ្តល់កម្មីតាមតំបន់ តាមប្រធានបទ តាមវិស័យ និងអានអំពីការប្រតិបត្តិរបស់ធនាគារពិភពលោក គំនិតផ្តួចផ្តើមថ្មី និងគោលដៅនិន្នាការក្នុងតំបន់ កម្មវិធី និងការងារនៅតាមមូលដ្ឋាន និងប្រធានបទ ដូចជាការបំរែបំរួលអាកាសធាតុ សុខភាព និងហេដ្ឋារចនាសម្ព័ន្ធ។

ការបោះពុម្ពផ្សាយ

វេបសាយ ៖ http://www.worldbank.org/publications

ស្វែងរកឯកសារបោះពុម្ពផ្សាយសំរាំងផ្លូវការរបស់ធនាគារពិភពលោកតាមប្រធានបទ តាមតំបន់ ឬតាមប្រទេស។ ការអានព័ត៌មានដោយឥតគិតថ្លៃនៅលើវេបសាយគឺអាចអានបានសម្រាប់ឯកសារដែលបានជ្រើសរើសមួយចំនួន។ ឯកសារបោះពុម្ភអាចរកបញ្ចាទិញបានក្នុងតំលៃមួយទាបសម្រាប់អតិថិជននៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។